ប្រញាប់ ដើម្បីមកទទួលអាឡាដាំង កុំឱ្យអាឡាដាំងឱនក្រាបថ្វាយបង្គំព្រះអង្គទាន់ នឹងដើម្បីឱបរឹតអ្នកកំលោះ ជាការសម្តែងនូវមេត្រីភាពដ៏ជ្រាលជ្រៅ ។ ក្រោយពីការសម្តែងមេត្រីភាពនេះមក, អាឡាដាំងចង់ឱនលុតជង្គង់ថ្វាយបង្គំព្រះបាទស៊ុលតង់ទៀត ប៉ុន្តែព្រះអង្គទ្រង់ចាប់ដៃបុរសជាប់ ហើយទាញបង្ខំឱ្យឡើងទៅអង្គុយនៅចន្លោះព្រះអង្គ នឹងលោកនាយករដ្ឋមន្ត្រី ។

នៅពេលនោះ, អាឡាដាំងក៏បញ្ចេញវាចាឡើងថា : "បពិត្រព្រះករុណាថ្លៃវិសេស, ទូលព្រះបង្គំបានទទួលកិត្តិយសពីព្រះអង្គក៏ព្រោះតែព្រះអង្គ សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានដល់ទូលព្រះបង្គំដែរ ។ ប៉ុន្តែសូមព្រះអង្គទ្រង់ព្រះរាជានុញ្ញាតឱ្យទូលព្រះបង្គំទូលថា ទូលព្រះបង្គំឥតមានភ្លេចថា ទូលព្រះបង្គំនេះ កើតមកជាខ្ញុំបម្រើព្រះអង្គ ទូលព្រះបង្គំបានស្គាល់ច្បាស់នូវឫទ្ធិអំណាចបារមីព្រះអង្គ ហើយទូលព្រះបង្គំក៏មិនមែនពុំដឹងដែរថា ទូលព្រះបង្គំកើតមកក្នុងត្រកូលដ៏ខ្សត់ខ្សោយថោកទាប ជាងព្រះអង្គឆ្ងាយក្រៃលែង រកហៅពុំឮឡើយ ។ ដូច្នេះ បើសិនជាមានលក្ខណៈត្រង់ណាមួយដែលធ្វើឱ្យទូលព្រះបង្គំអាចបានទទួលព្រះរាជបដិសណ្ឋារកិច្ច ដ៏ខ្ពង់ខ្ពស់ពីព្រះអង្គនោះ ទូលព្រះបង្គំសូមទូលដោយបរិសុទ្ធចិត្តថា ប្រហែលជាមកពីចក្ខុគំនិត និងបំណងរបស់ទូលព្រះបង្គំ ដែលចង់បានព្រះនាងម្ចាស់ក្សត្រីនោះខ្លាំងពន់ពេក ដែលជាកម្មវត្ថុនៃសេចក្តីប្រាថ្នារបស់



ទូលព្រះបង្គំ ។ ទូលព្រះបង្គំសូមឱ្យព្រះអង្គ មេត្តាព្រះរាជទានអភ័យទោសដល់រឿងនោះ ។ ខ្ញុំព្រះអង្គពុំអាចលាក់បានឡើយថា ខ្ញុំព្រះអង្គមុខជានឹងស្លាប់ ដោយសេចក្តីបារម្ភនេះពុំខាន បើសិនជាសេចក្តីសង្ឃឹមរបស់ទូលព្រះបង្គំពុំបានសម្រេច ។

- នែកូនប្រុស ! (ព្រះបាទស៊ុលតង់មានព្រះបន្ទូលតប ដោយចាប់អាឡាដាំង ឱបរឹតផ្ទាល់នឹងព្រះកាយទ្រង់ជាលើកទីពីរ) កូនឯងនៅសង្ស័យអ្វីទៀត នឹងព្រះរាជសាសន៍ដ៏ស្និទ្ធស្នាលរបស់បិតាឯងនោះ។ ពីថ្ងៃនេះទៅមុខ ជីវិតកូនឯង មានតម្លៃដល់ប៉ាខ្លាំងណាស់ គឺប៉ានឹងប្រគល់ឱសថមួយឱ្យឯង គឺប៉ាឱ្យកូនឯង មើលការខុសត្រូវជំនួសប៉ា ។ ប៉ាមានសេចក្តីរីករាយណាស់ ដោយបានឃើញ នឹងបានស្តាប់វាចាកូនឯង ។

លុះចប់ព្រះបន្ទូលនេះភ្លាម ព្រះបាទស៊ុលតង់ទ្រង់ធ្វើសញ្ញានឹងព្រះហស្តមួយសន្ទុះមកគេឮសូរសម្លេងត្រែប៉ី និងស្គរលាន់ឮរន្ធឺឡើង។ នៅពេលនោះ, ព្រះបាទស៊ុលតង់ ក៏នាំអាឡាដាំង ទៅក្នុងបន្ទប់ទទួលភ្ញៀវដ៏ស្អាតមួយ រួចគេក៏រៀបជប់លៀងឡើងភ្លាម ។ ព្រះបាទស៊ុល-តង់ទ្រង់សោយព្រះក្រយាជាមួយនឹងអាឡាដាំង ។ លោកនាយករដ្ឋមន្ត្រី នឹងមន្ត្រីទាំងឡាយក្នុងព្រះរាជវាំង ក៏អញ្ជើញទៅរកកន្លែងអង្គុយទទួលទានអាហារ តាមលំដាប់យសសក្តិ និងឋានៈ ។ ព្រះបាទស៊ុលតង់ ទ្រង់តែងតែចោលព្រះនេត្រទៅលើអាឡាដាំងជានិច្ច ដោយ

ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ នឹងទតអាឡាដាំង ។ ហេតុនោះហើយបានជានៅពេលនោះ គេសង្កេតឃើញព្រះបាទស៊ុលតង់ ទ្រង់មានព្រះរាជឱង្ការអំពីរឿងផ្សេងៗ ពុំចេះចប់ពុំចេះអស់ព្រះកាយពលឡើយ ។

នៅក្នុងការសន្ទនានោះ, អាឡាដាំងពោលយ៉ាងម៉ឺងម៉ាត់ច្បាស់ៗ ហើយប្រកបដោយគតិបណ្ឌិតផង អំពីរឿងអ្វីនីមួយៗ លុះត្រាតែព្រះបាទស៊ុលតង់ជឿជាក់ឥតមានសង្ស័យអ្វីឡើយ ។

លុះចប់ការជប់លៀង ព្រះបាទស៊ុលតង់ទ្រង់មានព្រះរាជឱង្ការត្រាស់ហៅចៅក្រមទីមួយនៅក្នុងព្រះរាជធានី ឱ្យធ្វើកិច្ចសន្យាអាពាហ៍ពិពាហ៍ ព្រះរាជបុត្រីព្រះអង្គជាមួយនឹងអាឡាដាំង ហើយឱ្យចម្លងឱ្យស្អាតត្រឹមត្រូវមួយរំពេច ។ នៅក្នុងពេលសន្ទនាគ្នានោះ លោកនាយករដ្ឋមន្ត្រី និងសេនាបតីទាំងឡាយក្នុងព្រះបរមរាជវាំង ស្ញើចសរសើរនូវគំនិតដ៏ឈ្លាសវៃ ក្នុងការនិយាយស្ដី នឹងបញ្ញាវាងវៃនៃអាឡាដាំងក្នុងការជជែក ។

លុះចៅក្រមធ្វើកិច្ចសន្យារួច ត្រឹមត្រូវតាមច្បាប់ហើយ ព្រះរាជាក៏សួរអាឡាដាំងថា : តើអាឡាំងចង់នៅទីនេះ លុះត្រាតែចប់ពិធីឬ? អាឡាដាំងក៏ឆ្លើយឡើងថា : “បពិត្រព្រះករុណាថ្លៃវិសេស ! ទូលព្រះបង្គំសូមថយពីទីនេះសិន. ដើម្បីសុំព្រះរាជានុញ្ញាតសង់ប្រាសាទមួយថ្វាយព្រះនាងគង់ ដើម្បីឱ្យសមទៅតាមព្រះរាជឋានៈ ។ ដូច្នេះខ្ញុំ



ព្រះអង្គសូមព្រះអង្គព្រះរាជទានកន្លែងត្រង់ណាមួយ ដោយសមរម្យនៅក្នុងព្រះរាជវាំងនេះ ដើម្បីទូលព្រះបង្គំ នឹងសង់ប្រាសាទ បំពេញព្រះទ័យព្រះនាង ។ ទូលព្រះបង្គំក៏ដឹងដែរថា ការនេះត្រូវធ្វើឱ្យហើយក្នុងពេលដ៏រូសរាន់នេះ” ។

– កូនប្រុស. (ព្រះបាទស៊ុលតង់ទ្រង់មានព្រះបន្ទូល) ចូរឯងរើសរកដីត្រង់កន្លែងណាតាមតែចិត្តឯងស្រឡាញ់ចុះ ។ នៅមុខព្រះរាជដំណាក់នេះ មាននៅសល់កន្លែងមួយធំណាស់ ដែលបិតាប្រុងនឹងសង់អ្វីមួយបំពេញដែរ ។ ប៉ុន្តែចូរកូនឯងកុំភ្លេចថា ដើម្បីធ្វើឱ្យបិតារីតសប្បាយព្រះទ័យនោះ, គ្មានអ្វីក្រៅពីធ្វើឱ្យបិតាបានឃើញកូនមកនៅរួមរក្សជាមួយនឹងព្រះរាជបុត្រីក្នុងពេលឆាប់ៗទេ ។ ចប់ព្រះរាជឱង្ការភ្លាម, ព្រះអង្គក៏ឱបរឹតខ្លួនអាឡាដាំងទៀត ។ នៅពេលនោះ, អាឡាដាំងក៏ក្រាបថ្វាយបង្គំលាព្រះមហាក្សត្រតាមរបៀបលាស្ដេច ហាក់ដូចជាបុរសនេះឯងបានកើតនៅក្នុងទីនោះ ហើយបានរស់នៅជានិច្ចកាលក្នុងទីនោះផង ។

អាឡាដាំងក៏ឡើងជិះសេះត្រឡប់ទៅផ្ទះវិញ ដោយមានក្បួនដង្ហែដដែល ដូចកាលពីពេលមក ។ នៅតាមផ្លូវមានប្រជាជនឈរមើលកកកុញណែនណាន់តាន់តាប់ ព្រមទាំងទះដៃស្រែកឱ្យពរអាឡាដាំងគ្រប់បែបគ្រប់យ៉ាងដូចកាលពីពេលមក ។ លុះទៅដល់ផ្ទះចុះពីខ្នងសេះរួច. អាឡាដាំងក៏ដើរចូលទៅក្នុងបន្ទប់ពិសេសមួយ. យក

ចង្កៀងមកត្រដុសហៅអារក្សដូចដែលបានធ្លាប់ធ្វើមក ។ អារក្សក៏ឥតបង្អង់យូរបានមកដល់ភ្លាម, អាឡាដាំងក៏និយាយថា : “អារក្ស ! ដោយសារការទៀងទាត់របស់អ្នកក្នុងការទទួលប្រតិបត្តិតាមសេចក្ដីបង្គាប់ខ្ញុំពុំដែលមានរំលងត្រង់កន្លែងណាសោះ, ក្រោមឥទ្ធិឫទ្ធិនៃចង្កៀងទិព្វ ដែលជាចៅហ្វាយអ្នក, ខ្ញុំក៏បានបំពេញបំណងខ្ញុំសព្វគ្រប់ទាំងអស់ ។ ប៉ុន្តែឥឡូវនេះ ដើម្បីជាសេចក្ដីស្នេហាដល់ព្រះនាង, ចូរអ្នកសង់ប្រាសាទ មួយនៅត្រង់កន្លែងទល់មុខនឹងប្រាសាទព្រះបាទស៊ុលតង់ឱ្យហើយឆាប់រហ័សរួសរាន់ទាន់ពេលវេលា ដែលអាចធ្វើបាន, ហើយឱ្យសមរម្យនឹងឋានៈព្រះនាងបាឌ្រួលប៊ូឌួរ ដែលជាភរិយារបស់ខ្ញុំផង ។ រីឯគ្រឿងសម្ភារៈសម្រាប់សង់ យើងបើកឱ្យឯងរើសយកតាមត្រូវការ គឺថាយកថ្មកែវក្រហមពពាល ឬត្បូងថ្ម, ឬក៏ថ្មកែវពណ៌ចម្រុះ, ឬមួយថ្មកែវពណ៌ផ្ទៃមេឃ, ឬមួយថ្មកែវសុទ្ធ ប៉ុន្តែនៅលើកំពូលប្រាសាទ, ខ្ញុំសូមឱ្យអ្នកធ្វើបន្ទប់ទទួលភ្ញៀវមួយមានរាងជាមណ្ឌប, មានមុខបួនទំហំស្មើគ្នា ដែលថ្នាក់ជើងជញ្ជាំង នីមួយៗមិនត្រូវយកវត្ថុអ្វីក្រៅពីមាស និងប្រាក់នោះមកតម្រៀបឆ្លាស់គ្នា, ហើយត្រូវមានបង្អួច ១២, ម្ខាង ៦, ហើយឯស្លាបព្រិល បង្អួចនីមួយៗ ត្រូវទុកតែបង្អួចមួយធ្វើកុំឱ្យហើយ ។ ឯបង្អួចឯទៀត ត្រូវធ្វើតែអំពីពេជ្រត្បូងកែវមរកត និងត្បូងទទឹម ដែលនៅក្នុង ពិភពលោកយើងនេះ គ្មានប្រាសាទដូច្នេះដល់ពីរឡើយ ។ មួយចំណែកទៀត ខ្ញុំត្រូវការឱ្យប្រាសាទ



នោះមានទីធ្លាពីរជាប់គ្នានឹងសួនឧទ្យានមួយ ។ ប៉ុន្តែពិសេសជាងគេគឺត្រូវមានឃ្លាំងដាក់រូបិយមួយដោយឡែកសម្រាប់ចាយឃ្លាំងនោះត្រូវសង់នៅកន្លែងណាមួយ ដែលអ្នកនឹងប្រាប់យើងជាខាងក្រោយ ។ នៅក្នុងប្រាសាទនោះទៀត ត្រូវមានរោងពិសេស (ផ្ទះចំអិនអាហារ) បន្ទប់ដឹកលក្រយាស្ងោយ, មន្ទីរឃ្លាំង, បន្ទប់ដាក់ គ្រឿងសង្ហារិមដែលមានសុទ្ធតែអច្ឆរិយវត្ថុ សម្រាប់ប្រើតាមរដូវ និងឱ្យសមរម្យទៅតាមលម្អប្រាសាទ ។ ក្រៅពីនេះ ត្រូវមានរោងសេះដែលមានដាក់សេះយ៉ាងល្អៗ ព្រមទាំងអ្នកឱ្យស្មៅសេះ និងអ្នកថែរក្សាសេះតែកុំភ្លេចត្រូវមានសេះ សម្រាប់ជិះទៅបរបាញ់សត្វផង ។ ទីបំផុតត្រូវមានពួកនាយពិសេស (អ្នកចំអិនអាហារ) ពួកអាមាត្យថែរក្សាបន្ទប់ដឹកលក្រយាស្ងោយ និងពួកស្រីបម្រើសម្រាប់គាល់បម្រើម្ចាស់ក្សត្រី ។ ត្រូវអ្នកចាំឱ្យច្បាស់នូវសេចក្ដីប្រាថ្នារបស់ខ្ញុំនេះ ដូច្នេះត្រូវអ្នកថយទៅវិញចុះ រួចត្រឡប់មកប្រាប់យើងវិញភ្លាម កាលណាការនេះ បានធ្វើរួចស្រេចហើយ ។

ព្រះអាទិត្យក៏អស្ដង្គតទៅ នៅពេលដែលអាឡាដាំងនិយាយប្រាប់អារក្ស អំពីរបៀបសង់ប្រាសាទចប់ហើយ ។ អំណាចសេចក្ដីស្នេហាដ៏ខ្លាំងក្លា ដែលអាឡាដាំងមានចំពោះព្រះនាង អាឡាដាំងពុំអាចនិទ្រាលក់ឡើយ ។ ដូច្នេះស្អែកឡើងគ្រាន់តែភ្លឺស្រាងៗ គេឃើញអ្នកកំឡោះក្រោកអង្គុយទៅហើយ ។ ក្រោកឡើងភ្លាម, អារក្សក៏ចូល

មកដល់និយាយប្រាប់អ្នកកំឡោះថា “ប្រាសាទរបស់លោកសង់រួចស្រេចហើយ. សូមអញ្ជើញលោកទៅមើល តើលោកពេញចិត្ត ឬពុំពេញចិត្ត” ។ អាឡាដាំងពុំទាន់ទាំងឆ្លើយថា ខ្ញុំចង់ឃើញប្រាសាទនោះណាស់ផង , អារក្សក៏លើកស្ទួយយកទៅដាក់ត្រង់កន្លែងនោះ ។ អាឡាដាំង ក៏ឃើញប្រាសាទនោះ ល្អលើសអំពីខ្លួនបានបង្គាប់ទៅទៀត ឈរសំឡឹងមើលស្ទើរពុំប៉ប្រិចភ្នែក ។ អារក្សនាំអាឡាដាំងដើរមើលសព្វកន្លុកកន្លៀតកៀនកោះទាំងអស់ហើយ នៅកន្លែងណាក៏ដោយ គេឃើញតែមាសប្រាក់ ពេជ្រកែវកង, គេឃើញតែស្អាត, តែល្អពណ្ណរាយ មានទាំងអាមាត្យ ទាំងខ្ញុំកំដរ, ស្លៀកពាក់តាមរបៀប, តាមមុខការដែលត្រូវធ្វើ (គឺស្លៀកពាក់តាមឋានៈរបស់ខ្លួន) ។ ក្រៅពីនេះ, អារក្ស ក៏មិនភ្លេចនាំអាឡាដាំង ទៅមើលវត្ថុដ៏សំខាន់ជាងគេមួយ គឺឃ្លាំងមាស ឃ្លាំងប្រាក់ ដែលមានហិរញ្ញិកម្នាក់ចេញ មកបើកទ្វារឱ្យ ។ ក្នុងឃ្លាំងនោះ មានដាក់សុទ្ធតែថង់មាស, មានទំហំធំតូចអាស្រ័យតាមរូបិយ ដែលច្រកនៅក្នុងថង់នោះ ។ ថង់ទាំងនោះ ដាក់គរទល់ដល់ពិតាន ហើយមានរបៀបរៀបរយ ល្អគួរជាទីគយគន់ណាស់ ។ ចេញពីឃ្លាំងនោះមកវិញ អារក្សក៏នាំអាឡាដាំងទៅមើលរោងសេះ នៅក្នុងនោះអារក្សបង្ហុលបង្ហាញអាឡាដាំងឱ្យសង្កេតមើលសេះដ៏ល្អៗ ជាងសេះឯទៀត ដែលមាននៅក្នុងលោក នឹងមើលពួកកម្មករថែរក្សាសេះកំពុងដុសលាងសេះ ។ តមកទៀតអារក្សនាំអា-



ឡាដាំងដើរមើលឃ្លាំងដាក់គ្រឿងប្រដាប់សម្រាប់តុបតែងសេះ និងចំណីអាហារសម្រាប់ឱ្យវាស៊ី ។

កាលអាឡាដាំងបានមើលប្រាសាទពីដំណាក់មួយទៅមួយ ពីបន្ទប់មួយទៅបន្ទប់មួយ ចាប់តាំងពីថ្នាក់លើមកទល់ថ្នាក់ក្រោម, ពិសេសគឺ បន្ទប់ទទួលភ្ញៀវ ដែលមានបង្អួច២៤ និងក្រោយដែលបានឃើញនៅក្នុងប្រាសាទនោះ សុទ្ធតែមាសពេជ្រប្រាក់កែវកងពិទូរ្យសូរ្យកាន្ត សុទ្ធតែជាកន្លែងល្អឆើតឆាយ ពណ្ណរាយ សុទ្ធតែជាកន្លែងរុងរឿងសប្បាយ ហួសឆ្ងាយពីគំនិតខ្លួន ដែលបង្គាប់អារក្សឱ្យធ្វើទៅទៀត អ្នកកំលោះក៏និយាយ ទៅកាន់អារក្សថា : “អារក្ស ! ក្នុងពេលនេះគ្មាននរណាសប្បាយចិត្តជាងខ្ញុំឡើយ ហើយគ្មានរឿងហេតុត្រង់កន្លែងណា ដែលអាចធ្វើឱ្យខ្ញុំទោមនស្សនោះឡើយ ។ នៅសល់តែរឿងមួយទៀតទេ ដែលខ្ញុំពុំទាន់បាននិយាយប្រាប់ឯង ព្រោះខ្ញុំនឹកពុំឃើញ គឺសុំឱ្យឯងយកព្រំយ៉ាងល្អឆើតជាងគេ មកក្រាលលើផ្លូវចាប់តាំងពីមាត់ទ្វារប្រាសាទព្រះបាទស៊ុលតង់ ទៅទល់មាត់ទ្វារនៃព្រះរាជដំណាក់ សាងថ្វាយព្រះនាង នៅក្នុងប្រាសាទនេះ ដើម្បីឱ្យព្រះនាងយាងដើរលើកម្រាលនោះ នៅពេលយាងចេញពីប្រាសាទស៊ុលតង់មក” ។ អារក្សក៏ឆ្លើយថា : ខ្ញុំនឹងត្រឡប់មកបំពេញកិច្ចនេះមួយរំពេច ។ លុះអារក្សអន្តរធានបាត់ទៅមួយស្របក់ក្រោយមក អាឡាដាំងក៏មានសេចក្តីងឿងឆ្ងល់ជាក្រៃលែង ដោយឃើញវត្ថុបំណងរបស់ខ្លួន បានត្រូវតែ

បំពេញឱ្យរួចជាស្រេច ដោយឥតទាំងបានឃើញគេធ្វើដូចម្តេចផង ។ អារក្សចេញមកបង្ហាញខ្លួនជាថ្មី រួចលើកអាឡាដាំងយកទៅដាក់ឯផ្ទះវិញ នៅពេលដែលគេបើកទ្វារប្រាសាទ ព្រះបាទស៊ុលតង់ ។

ពួកទ្វារបាលទាំងឡាយ ដែលទើបតែចេញមកបើកទ្វារប្រាសាទ ធ្លាប់តែឃើញទីត្រង់កន្លែងប្រាសាទអាឡាដាំង ពីដើមឡើយទទេស្អាត គ្មានគេហស្ថានអ្វីមួយសោះក៏កើតសេចក្តីងឿងឆ្ងល់ ជាពន់ពេក កាលបើបានឃើញប្រាសាទនោះ ហើយនិងកម្រាលព្រំ ដែលគេក្រាលចាប់តាំងពីប្រាសាទស៊ុលតង់ ។ នាយទ្វារបាលទាំងនោះដំបូងឡើយពុំបានពិនិត្យមើលអច្ឆរិយវត្ថុដោយម៉ត់ចត់ទេ ប៉ុន្តែជនទាំងនោះកើតសេចក្តីស្ញប់ស្ញែងជាខ្លាំង។ លុះបានមើលប្រាសាទអាឡាដាំងសព្វគ្រប់កន្លែងទៅ ។ មិនយូរប៉ុន្មានដំណឹងនេះ ក៏ឮខ្ចរខ្ចាយ ពេញព្រះបរមរាជវាំង ។ ក្រោយបន្តិចមកលោកនាយករដ្ឋមន្ត្រីបាន អញ្ជើញមកដល់ក៏កើតសេចក្តីងឿងឆ្ងល់ នឹងវត្ថុចម្លែកនេះមិនតិចជាងអ្នកដទៃឡើយ។ លោកក៏នាំរឿងនេះទៅក្រាបទូលព្រះបាទស៊ុលតង់មុនគេ បង្អស់, ប៉ុន្តែលោកចង់ទូលព្រះអង្គថា របស់នេះកើតឡើងបានដោយសារមន្តអាគមសិល្បសាស្ត្រទេ ។ ព្រះបាទស៊ុលតង់ក៏មាន ព្រះបន្ទូលឡើងថា: "លោកនាយក ! ចុះហេតុអ្វីបានជាលោកចង់ ថារបស់នេះកើតឡើងដោយសិល្បសាស្ត្រ លោកដឹងជាងខ្ញុំទៅទៀតថា នេះមិនមែនប្រាសាទដែលអាឡាដាំងបានសាងថ្វាយព្រះអង្គម្ចាស់ក្សត្រីជា បុត្រីខ្ញុំតាម



សេចក្តីអនុញ្ញាតរបស់ខ្ញុំ ដែលខ្ញុំបានយល់ព្រមឱ្យដល់បុរសនោះ នៅចំពោះមុខលោកទេឬ? តាមតម្លៃទ្រព្យសម្បត្តិដែលយើងឃើញនេះ, តើយើងអាចឆ្ងល់ថា ចុះហេតុអ្វីក៏គាត់ធ្វើប្រាសាទនេះឆាប់ម្ល៉េះ? ។ ត្រង់នេះគេចង់បង្ហាញឱ្យយើងដឹងថា តែកាលណាគេមានប្រាក់គ្រប់គ្រាន់ហើយ, គេអាចធ្វើការអ្វីឱ្យបានសម្រេចនៅថ្ងៃ ណាពេលណាមួយក៏បាន ។ សូមលោកមានប្រសាសន៍ ប្រាប់ខ្ញុំឱ្យត្រង់មកថា ពាក្យដែលលោកចង់ពោលថា របស់នេះកើត ដោយសារតែមន្តអាគមនោះគឺលោកពោលដោយមានចិត្តច្រណែន បន្តិចហើយមែនទេ, លោកនាយក" ។ ពេលត្រូវចូលជំនុំការក៏មក ផ្តាច់ការសន្ទនារវាងព្រះបាទស៊ុលតង់ នឹងលោកនាយកត្រឹមនេះ ។

នៅពេលដែលអាឡាដាំង ត្រូវអារក្សលើកយកទៅដាក់ដល់ផ្ទះ, និងក្រោយពីបានអនុញ្ញាតឱ្យអារក្សថយខ្លួនចេញ, អ្នកកំលោះក៏ក្រឡេកឃើញម្តាយក្រោកពីសម្រាន្ត កំពុងតែងកាយនឹងសម្លៀកបំពាក់ ដែលខ្លួនបានឱ្យគេយកមកជូនគាត់ ។ ប្រហែលជិតដល់ពេលព្រះបាទស៊ុលតង់យាងចេញពីរោងជំនុំ អាឡាដាំងក៏ជម្រាបអញ្ជើញម្តាយឱ្យទៅវាំងជាមួយ នឹងស្រីបម្រើដែលអារក្សនាំមកជូន ។ អ្នកកំឡោះនិយាយអង្វរម្តាយថា បើសិនជាគាត់បានជួបនឹងព្រះបាទស៊ុលតង់ សូមទូលព្រះអង្គថា គាត់មកនេះដើម្បីនឹងបានទទួលកិត្តិយសដង្ហែព្រះបាទនៅវេលាល្ងាច, ដែលព្រះនាងរៀបចំយាងទៅប្រាសាទ

ដែលគេបានសាងថ្វាយព្រះនាង ។ ដូច្នេះម្ដាយអាឡាដាំងក៏អញ្ជើញចេញទៅ ។ ប៉ុន្តែបើទុកជាគាត់នឹងស្រីបម្រើ ដែលដើរពីក្រោយតែងតួស្លៀកពាក់ដូចជាព្រះមហាក្សត្រីយានី ដែលគេធ្លាប់បានឃើញនោះក៏ដោយ, ក៏ពួកមនុស្សនៅតែពុំតិចឡើយ មកឈរចោមរោមមើលគាត់ នឹងស្រីបម្រើដែលសុទ្ធតែរុំមុខ នឹងសំពត់ស្បៃដ៏ស្ដើងព្រមទាំងមានគ្រឿងអលង្ការស្រោបលើសម្លៀកបំពាក់រៀងៗខ្លួនទៀត។ ចំណែកឯអាឡាដាំងវិញ អ្នកជិះនៅលើខ្នងអស្សតរ ។ មុននឹងចាកចេញពីទីលំនៅព្រះបិតាទៅកាលណា អ្នកកំលោះឥតភ្លេចយកចង្កៀងទិព្វនេះទៅតាមឡើយ ព្រោះចង្កៀងនេះហើយ ដែលបានជួយយកអាសាអ្នកជាច្រើនក្រៃលែង លុះត្រាតែអ្នកមកជួបប្រទះនឹងសុភមង្គលដ៏ឧត្តមដូច្នេះ ។ លុះអ្នកយកចង្កៀងមកកាន់នៅដៃ ហើយអ្នកក៏បរពាជីតម្រង់ទៅព្រះរាជវាំង ដោយមានសភាពអធិកអធមដូចកាល ដែលខ្លួនបានចូលទៅគាល់ព្រះបាទស៊ុលតង់ពីលើកមុនដែរ ។

ពួកទ្វារបាល កាលបើបានឃើញម្ដាយអាឡាដាំងទៅដល់, ក៏រត់ម្នីម្នាទៅទូលព្រះករុណាជាម្ចាស់ជីវិតលើត្បូង ។ មួយរំពេចក៏មានបង្គាប់មកដល់ពួកក្រុមទាហានផ្លុំត្រែ, វាយស្គរ, នឹងខ្លុយសាដៀវដែលបានមកឈរចាំគំនាប់នៅកន្លែងរៀងៗខ្លួនស្រាប់ នៅក្នុងខឿនព្រះបរមរាជវាំង ឱ្យប្រុងប្រៀបខ្លួន ។ ក្រោយបន្តិចមក, សម្លេងតូរ្យតន្ត្រីក៏បង្ហើរ នូវការសប្បាយពាសពេញព្រះរាជធានី ។ ពាណិជ



ទាំងឡាយ ក៏ចាប់រៀបចំតុបតែងហាងខ្លួននឹងសំពត់កម្រាលដ៏ល្អៗ, មានខ្មៃយកើយនិងស្លឹករុក្ខជាតិជាដើម ព្រមទាំងរៀបចំដាក់ភ្លើងសម្រាប់អុជបំភ្លឺនៅវេលាយប់ទៀត ។ ពួកកម្មករគ្រប់ប្រភេទបានឈប់សម្រាកធ្វើការ ប្រជាជនដទៃក៏ដើរយ៉ាងប្រញិបប្រញាប់តម្រង់ទៅទីលានដ៏ធំ ឋិតនៅចន្លោះប្រាសាទព្រះបាទស៊ុលតង់ នឹងប្រាសាទអាឡាដាំង ។

ប៉ុន្តែ ប្រជាជនបានយកចិត្តទុកដាក់មើលប្រាសាទអាឡាដាំងជាទីបំផុត ។ ការនេះគឺមិនមែនមកពីប្រជាជនធ្លាប់បានឃើញប្រាសាទព្រះបាទស៊ុលតង់ហើយៗ មិនសូវចង់មើលទៀតនោះទេ គឺមកពីប្រាសាទព្រះបាទស៊ុលតង់ មិនអាចមានលម្អប្រៀបទៅនឹងប្រាសាទអាឡាដាំងបាន ។ ប៉ុន្តែបុព្វហេតុនៃការងឿងឆ្ងល់ដ៏ធំបំផុតរបស់ជនទាំងនោះ គឺការងឿងឆ្ងល់ថា តើគេធ្វើវត្ថុដ៏ល្អអស្ចារ្យដូច្នេះអ្វីក៏ហើយឆាប់ម្លេះ, ព្រោះពីថ្ងៃមុននៅត្រង់ទីនេះគេគ្មានឃើញគ្រឿងសម្ភារៈគ្មានឃើញទំនងការអ្វីដែលអាចឱ្យគេស្មានបានថា នឹងមានការប្រុងប្រៀបសង់អ្វីនោះសោះឡើយ ។

ម្ដាយអាឡាដាំង បានទទួលកិត្តិយសយ៉ាងខ្ពង់ខ្ពស់ក្នុងការអញ្ជើញចូលទៅក្នុងព្រះបរមរាជវាំង ។ បន្ទាប់ពីនោះ នាយមនុស្សកម្រៀវក៏នាំគាត់ចូលទៅក្នុងដំណាក់ព្រះនាងបាឌ្រូលប៊ូឌូរ ។ លុះព្រះនាងទតឃើញភ្លាម ក៏ស្ទុះមកឱបរឹតម្ដាយអាឡាដាំង, ហើយអញ្ជើញ

គាត់ឱ្យអង្គុយលើកៅអីវែង ។ នៅពេលទម្រាំតែស្រីបម្រើស្លៀកពាក់ និងតុបតែងកាយនឹងសំពត់ព្រមទាំងគ្រឿងអលង្ការ ដែលអាឡាដាំង បានជូនឱ្យរួច, ព្រះនាងក៏រៀបចំចំណីអាហារយ៉ាងល្អៗ ជូនគាត់ពិសា។ ចំណែកឯព្រះបាទស៊ុលតង់ ដែលបានយាងមកកំសាន្តលេងជាមួយនឹង ព្រះរាជបុត្រីព្រះអង្គមុនពេលដែលព្រះរាជបុត្រីត្រូវបែកចេញពីព្រះ អង្គ ទៅគង់ឯប្រាសាទអាឡាដាំងវិញនោះ ក៏បានសំដែងព្រះរាជគារ-វកិច្ច និងបដិសណ្ឋារកិច្ចដល់ម្តាយអាឡាដាំងយ៉ាងសមគួរជាទីបំផុតដែរ ។ ម្តាយអាឡាដាំង បាននិយាយទៅកាន់ព្រះបាទស៊ុលតង់នៅគ្រប់កន្លែងជាច្រើនលើកច្រើនគ្រា ប៉ុន្តែព្រះបាទស៊ុលតង់ ឥតដែលបានឃើញមុខម្តាយអាឡាដាំងផ្ទាល់ ដោយឥតរំស្បៃដូចជានៅពេលនេះទេ ។ ពិតមែនតែគាត់មានអាយុជឿនបន្តិច ហើយប៉ុន្តែគេសង្កេតឃើញទឹកមុខគាត់ មានលម្អគួរឱ្យគេសន្និដ្ឋានបានថា កាលគាត់នៅពីក្រមុំ គាត់មានរូបឆោមលោមពណ៌ល្អពិតប្រាកដ។ គឺគាត់បានត្រូវគេចាត់ចូលក្នុងពពួកនារី ដែលមានរូបសម្បត្តិឆើតឆាយ នឹងគេដែរ ។ ព្រះបាទស៊ុលតង់ ដែលទ្រង់ធ្លាប់តែឃើញ ម្តាយអាឡាដាំងស្លៀកពាក់យ៉ាងមធ្យម ដើម្បីកុំឱ្យគេថាគាត់ក្រពេកនោះ លុះម្តងនេះឃើញគាត់ស្លៀកពាក់យ៉ាងហឺហាល្អឆើតឆាយជាងព្រះរាជបុត្រីព្រះអង្គទៅទៀត។ ព្រះអង្គក៏ទ្រង់ទតរូបគាត់ជាយូរ ។ ការនេះធ្វើឱ្យព្រះអង្គទ្រង់ព្រះតម្រិះឈ្វេងថា អាឡាដាំងជាមនុស្សមានស្មារតីប្រុងប្រយ័ត្នមានគំនិតគិតគ្រប់ចំពោះកិច្ចការផ្សេងៗ មិនមានរាយមាយឡើយ ។



លុះពេលរាត្រីចូលមកដល់, ព្រះនាងម្ចាស់ក្សត្រីក៏ថ្វាយបង្គំលាព្រះបាទស៊ុលតង់ជាព្រះបិតា ។ ការលាគ្នានេះ បណ្តាលឱ្យមានចិត្តទោរទន់ និងបង្ហូរទឹកព្រះនេត្រជាច្រើន ។ ទាំងពីរព្រះអង្គបិតានិងកូនឱបរឹតគ្នាជាច្រើនគ្រាដោយឥតមានបញ្ចេញព្រះរាជឱង្ការមួយព្រះឱស្ឋឡើយ រួចព្រះបាទម្ចាស់ក្សត្រីក៏យាងចេញពីព្រះរាជដំណាក់ដោយមានម្តាយអាឡាដាំងដើរហែនៅខាងឆ្វេង, ស្រីបម្រើ១០០ នាក់ស្លៀកពាក់យ៉ាងឆើតឆាយពណ្ណរាយ ដើរហែពីក្រោយ ។ ពួកអ្នកលេងភ្លេងទាំងឡាយដែលបានលេងមកជាប់ជានិច្ចតាំងពីពេលម្តាយអាឡាដាំងមកដល់ ក៏ចាប់លេងភ្លេងបទចរលីលា ។ ក្រៅពីពួកស្រីបម្រើ១០០នាក់នោះ, មានពួកទាហាន ១០០នាក់ និងពួកមនុស្សកម្រេវសម្បុរខ្មៅ ដែលមានចំនួនស្មើគ្នាដែរ ព្រមទាំងពួកនាយទាហាននៅពីមុខដើរជាពីរជួរហែព្រះនាងពីក្រោយផង ។ ពួកសេនាមាត្យព្រះបាទស៊ុលតង់ចំនួន៤០០នាក់ ដែលដើរនៅសងខាងផ្លូវ, អុជចង្កៀងខ្លាញ់គោមួយម្នាក់កាន់នៅដៃចោលពន្លឺភ្លឺព្រោងព្រាតបាក់ដូចជាពេល ថ្ងៃ ព្រោះបានពន្លឺភ្លើងចាំងពីប្រាសាទព្រះបាទស៊ុលតង់ និងប្រាសាទអា-ឡាដាំងជួយផង ។

ព្រះនាងទ្រង់យាងលើព្រាំ ដែលក្រាលសន្ទឹងតាំងពីប្រាសាទព្រះបាទស៊ុលតង់ ទៅទល់នឹងប្រាសាទអាឡាដាំង ។ ហើយនៅពេលដែលព្រះនាងកំពុងយាង ក្រុមតូរ្យតន្ត្រី ដែលដើរនៅមុខក្បួន បានទៅ

ដល់ជិតប្រាសាទអាឡាដាំង ។ នៅពេលនោះ ក្រុមតូរ្យតន្ត្រី ដែលនៅថ្នាក់លើនៃប្រាសាទអាឡាដាំង ក៏ចាប់លេងឡើងដែរ បណ្តាលឱ្យលាន់ឮច្របូកច្របល់គ្នារំពងអឹងកង ជាហេតុនាំឱ្យរឹតតែកើតការសប្បាយខ្លាំងឡើងៗ ថែមទៀត ។ ការសប្បាយនេះ មិនមែនកើតមានឡើងតែនៅក្នុងកន្លែងដែលមានប្រជាជនយ៉ាងសម្បើមដូច្នេះប៉ុណ្ណោះទេ, គឺនៅក្នុងប្រាសាទទាំងពីរ នៅក្នុងទីក្រុងទាំងមូល និងនៅឆ្ងាយក្រៅពីទីនេះទៅទៀត ក៏ការសប្បាយនេះមានអនុភាពដ៏ខ្លាំងក្លាដែរ ។

ទីបំផុត ព្រះនាងក៏យាងទៅដល់មហាប្រាសាទថ្មី, អាឡាដាំងខំរត់ចេញមកចាំទទួលព្រះនាង នៅមាត់ទ្វារចូលទៅព្រះរាជដំណាក់ប្រកបដោយបីតិសោមនស្សក្រៃលែង ។ ម្តាយអាឡាដាំង ដែលឈរនៅកណ្តាលនាម៉ឺនសព្វមុខមន្ត្រីកំពុងខំយកចិត្តទុកដាក់ ពិនិត្យប្រៀបធៀបកូនគាត់ទៅនឹងព្រះអង្គម្ចាស់ក្សត្រីតើសមគ្នាឬទេ? ។ ចំណែកឯព្រះអង្គម្ចាស់ក្សត្រីវិញ លុះបានឃើញអាឡាដាំងកាលណា ក៏ទ្រង់សព្វព្រះរាជហឫទ័យស្រឡាញ់ពេញចិត្តជាក្រៃលែង ។ នៅពេលនោះអាឡាដាំងក៏ចូលទៅជិតព្រះនាង, សម្តែងសេចក្តីគួរសម រួចនិយាយថា : "ឱព្រះអង្គម្ចាស់ជាទីស្នេហារបស់ខ្ញុំ បើសិនជាទូលព្រះបង្គំ មានធ្វើអំពើអ្វីពុំគាប់គួរនាំឱ្យព្រះនាងពុំសព្វព្រះរាជហឫទ័យនោះៗ គឺជាអំពើកើតឡើងដោយអចេតនា បណ្តាលមកពីទូលព្រះបង្គំ មានសេចក្តីប្រាថ្នាចង់បានព្រះអង្គម្ចាស់ពេក ហើយបើសិនជាអំពើនេះមាន



មែនទូលព្រះបង្គំហ៊ានទូលព្រះនាងឱ្យត្រង់ថា គឺមិនមែនមកពីទូលព្រះបង្គំទេ គឺពិតជាកើតឡើងដោយសារ ដួងចក្ខុដ៏ថ្លា និងសម្រស់ព្រះកាយព្រះនាង" ។ ព្រះនាងបាឌ្រូលប៊ូឌូរក៏ឆ្លើយថា : "ព្រះអង្គម្ចាស់ គឺនៅពេលនេះហើយ ដែលខ្ញុំម្ចាស់ត្រូវហៅដូច្នេះ, ខ្ញុំម្ចាស់នឹងទទួលធ្វើតាមឆន្ទៈរបស់ឪពុកខ្ញុំម្ចាស់ទាំងអស់ ដោយឥតមានទីទើរក្នុងចិត្តឡើយ" ។

អាឡាដាំង សប្បាយរីករាយពេញចិត្តនឹងចម្លើយនេះពន់ប្រមាណ ក៏ចូលទៅចាប់ព្រះហស្តព្រះនាងថើបបញ្ចេញនូវសេចក្តីសប្បាយយ៉ាងក្រៃលែង រួចក៏យាងព្រះនាងទៅក្នុងបន្ទប់ទទួលភ្ញៀវដ៏ធំមួយមានភ្លើងទៀនរាប់ពុំអស់ចាំងព្រោងព្រាត ដើម្បីកុំឱ្យព្រះនាងទ្រង់គង់ឈរយូរឡើយ ព្រោះព្រះនាងពុំធ្លាប់គង់ដូច្នេះទេ ។ ដោយសារការទំនុកបម្រុងនៃអារក្សនៅលើតុក្នុងបន្ទប់នោះ គេឃើញមានម្ហូបចំណីយ៉ាងពោរពាស សម្រាប់ទទួលជប់លៀងព្រះនាង ។ ចានដាក់ម្ហូបចំណីបរិភោគសោត សុទ្ធតែធ្វើអំពីមាសយ៉ាងក្រាស់ៗ ។ ម្ហូបអាហារទាំងនោះទៀត ក៏សុទ្ធតែចម្អិនធ្វើអំពីសាច់សត្វដ៏មានឱជារសពន់ប្រមាណ ។ ថាសស្លកសម្រាប់ដាក់ចាននិងកែវសម្រាប់ដាក់ទឹក ដែលដាក់នៅពេញទូចានក៏សុទ្ធតែធ្វើអំពីមាស ហើយការធ្វើនេះទៀត ក៏ល្អស្អាតបានត្រឹមត្រូវជាក្រៃលែង ។ គ្រឿងរចនា និងគ្រឿងលម្អទាំងឡាយឯទៀតក្នុងបន្ទប់នោះ ក៏សែនសក្តិសមគ្នា និងគ្រឿងឧបករណ៍

ទាំងនោះ ជាក្រៃលែងដែរ ។ ព្រះអង្គម្ចាស់ក្សត្រីបាឡ្រលប៊ូឌូរ ទ្រង់សព្វព្រះរាជហឫទ័យពន់ប្រមាណ នឹងទ្រព្យសម្បត្តិដ៏សម្បូណ៌ហូរហៀរដាក់គំកល់ក្នុងកន្លែងមួយជាមួយគ្នាដូច្នេះ ក៏អត់ទ្រាំពុំបានមានព្រះសវនីយ៍ សួរទៅអាឡាដាំងថា : "ព្រះអង្គម្ចាស់ពីដើមមកខ្ញុំម្ចាស់នឹកស្មានថា នៅលើពិភពលោកយើងនេះគ្មានកន្លែងឯណា ល្អប្រសើរជាងប្រាសាទបិតាខ្ញុំម្ចាស់ឡើយ" ។ តែលុះដល់ខ្ញុំម្ចាស់បានមកឃើញបន្ទប់ព្រះអង្គ តែមួយប៉ុណ្ណោះ ក៏ខ្ញុំម្ចាស់ភ្ញាក់ខ្លួនព្រើតថា ការដែលខ្ញុំម្ចាស់បានស្មាននោះ វាខុសស្រឡះសោះ ។

- ព្រះអង្គម្ចាស់ក្សត្រី ! (អាឡាដាំងឆ្លើយ ដោយយាងព្រះនាងឱ្យគង់លើកៅអី ដែលគេទុកថ្វាយ) ទូលបង្គំបានសេចក្ដីសរសើរដ៏ស្មោះត្រង់ពីព្រះនាងមែន ប៉ុន្តែទូលបង្គំអាចស្គាល់បានដឹងបានតែនូវកិច្ចការណាដែលទូលបង្គំត្រូវជឿ ។

ព្រះអង្គម្ចាស់ក្សត្រីបាឡ្រលប៊ូឌូរ, អាឡាដាំង និង ម្ដាយក៏អង្គុយសោយនិងទទួលទានម្ហូបអាហារ ។ វង់តូរ្យតន្ត្រី ដែលពីរោះជាងគេក៏ចាប់លេងឡើងឮសូររំពង លុះពេលបាយរួចទើបឈប់ ដោយមានស្រី៧ដែលមានរូបឆោមល្អឆើតឆាយច្រៀងបន្ទរផង ។ ព្រះអង្គម្ចាស់ក្សត្រីកើតសេចក្ដីរីករាយជាក្រៃលែង ក៏លាន់ព្រះឱស្ឋថាព្រះបាទឥតដែលបានស្ដាប់ភ្លេងដ៏ពីរោះ ដូច្នេះនៅក្នុងប្រាសាទព្រះបិតាព្រះនាងសោះ ។ ព្រះនាងមានព្រះសវនីយ៍ដូច្នេះមកពីព្រះនាងមិនទ្រង់



ជ្រាបថា ពួកស្រីលេងតូរ្យតន្ត្រីទាំងនេះ សុទ្ធតែជាស្រីទេពអប្សរបរិវារកញ្ញា ដែលអារក្សបរិវារចង្កៀងជ្រើសរើសយកមកទេ ។

លុះពេលបាយរួច គេក៏លើកយកចានក្បានចេញភ្លាមនាដករនាដការីមួយក្រុម ក៏ចេញមករាំមួយរំពេច តាមចង្វាក់នៃភ្លេងដែលលេងដោយពួកស្រី៧ទៀត ។ គេរាំបញ្ចេញក្បាច់គ្រប់បែបគ្រប់យ៉ាងតម្រូវទៅតាមទំនៀមទម្លាប់នៃប្រទេស។ មុននឹងបញ្ចប់នាដករម្នាក់និងនាដការីម្នាក់ រាំបញ្ចេញសិល្បៈយ៉ាងរស់រវើកយ៉ាងប៉ិនប្រសប់ជាក្រៃលែង។ ពេលជិតនឹងអធ្រាត្រទៅហើយ ទើបអាឡាដាំងក្រោកពីកៅអី ហុចដៃនាំព្រះនាងរាំជាមួយ ដើម្បីបញ្ចប់កិច្ចមង្គលនេះ ។ នេះជាទំនៀម ដែលមាននៅប្រទេសចិនកាលជំនាន់នោះ។ អាឡាដាំងនឹងព្រះអង្គម្ចាស់ក្សត្រីរាំយ៉ាងល្អត្រូវបានសេចក្ដីសរសើរពីពួកអ្នកមើលជាច្រើន។ លុះរាំចប់អាឡាដាំងឥតលែងព្រះហស្តព្រះនាងឡើយ អ្នកដឹកព្រះហស្តព្រះនាងយាងចូលទៅក្នុងដំណាក់ ដែលមានគ្រែសម្រាប់ផ្ទំដំណេករៀបចំទុកជាស្រេច ។ ពួកស្រីបម្រើព្រះអង្គម្ចាស់ក្សត្រីក៏ចូលមកជួយដោះសម្លៀកបំពាក់ និងផ្ដេកព្រះនាងទៅលើគ្រែ។ ឯអាឡាដាំងក៏មានមនុស្សជួយធ្វើដូច្នោះដែរ លុះហើយកិច្ចភ្លាម,មនុស្សបម្រើទាំងអស់ ក៏ថយចេញរៀង១ខ្លួន ។ ការរៀបអភិសេកព្រះនាងបាឡ្រលប៊ូឌូរ និងអាឡាដាំងក៏សន្មតថាចប់ត្រឹមនេះ ។

ថ្ងៃស្អែកឡើង, លុះអាឡាដាំងភ្ញាក់ពីដំណេកពួកស្រីបម្រើ

ផ្ទាល់ ក៏ចូលមកជួយស្លៀកពាក់ខោអាវឱ្យ, តែសម្លៀកបំពាក់ក្រោយនេះ ខុសគ្នាពីសម្លៀកបំពាក់ ដែលអាឡាដាំងស្លៀកនៅថ្ងៃរៀបការហើយល្អជាងផង ។ បន្ទាប់មកប្រុសស្នេហ៍ក៏ឱ្យគេនាំសេះផ្ទាល់ខ្លួនមួយមក អ្នកឡើងជិះរួចបរតម្រង់ទៅប្រាសាទព្រះបាទស៊ុលតង់, កណ្ដាលហ្វូង ពួកទាសាទាសីដែលដើរអមពីមុខពីសងខាង និងពីក្រោយ។ ព្រះបាទស៊ុលតង់ ក៏ទទួលអាឡាដាំងយ៉ាងរាក់ទាក់ដូចជាពីលើកមុនដែរ។ គឺព្រះអង្គស្ទុះមកឱបរឹតអាឡាដាំង ។ រួចក្រោយដែលបានមានព្រះ បន្ទូលឱ្យអាឡាដាំងអង្គុយនៅជិតព្រះអង្គហើយព្រះអង្គក៏ទ្រង់បង្គាប់ឱ្យគេរៀបចំក្រយាស្ងោយ ។ ពេលនោះអាឡា-ដាំងក៏ទូលឡើងថា : "បពិត្រព្រះករុណាថ្លៃវិសេស ! ទូលព្រះបង្គំសូមកុំឱ្យព្រះអង្គរវល់នឹង រៀបទទួលទូលព្រះបង្គំឱ្យសោះ។ ទូលព្រះបង្គំមកនេះ ដើម្បីនាំព្រះអង្គទៅសោយព្រះក្រយាស្ងោយ នៅក្នុងប្រាសាទព្រះនាងជាមួយនឹងលោកនាយករដ្ឋមន្ត្រី និងនាម៉ឺនសព្វមុខមន្ត្រីនៅក្នុងព្រះបរមរាជវាំងម្ដង" ។ ព្រះបាទស៊ុលតង់ ក៏ទ្រង់ទទួលសេចក្ដីនេះដោយព្រះទ័យសោមនស្ស ។ ដូច្នេះព្រះអង្គក៏យាងចាកព្រះទែនមួយរំពេច ហើយដោយសារទីដែលព្រះអង្គត្រូវយាងទៅនោះនៅជិតទ្រង់ក៏សព្វព្រះរាជហឫទ័យយាងនឹងព្រះបាទផ្ទាល់, អាឡាដាំងនៅអមខាងស្ដាំ, លោកនាយករដ្ឋមន្ត្រីខាងឆ្វេង កុង្សីយ៍សេនាបតីនៅបន្ទាប់, ពួកទាហានរក្សាព្រះអង្គ និងពួកនាយទាហាននៅពីខាងក្រោយ ។



ដរាបណាព្រះបាទស៊ុលតង់ យាងចូលទៅជិតប្រាសាទអាឡា-ដាំងបន្តិច ដរាបនោះព្រះអង្គក៏កាន់តែឃើញល្អបន្តិចម្ដង១ដែរ ។ ប៉ុន្តែអស្ចារ្យបំផុត នៅពេលដែលព្រះអង្គយាងចូលទៅដល់ខាងក្នុងព្រះអង្គលាន់ព្រះឱស្ឋ សរសើរគ្រប់តែកន្លែងដែលទ្រង់បានទត ។ ពិសេស គឺលុះដល់ព្រះអង្គយាងឡើងទៅដល់បន្ទប់ទទួលភ្ញៀវ ដែលមានបង្អួច ២៤។ ព្រះអង្គទៅជាគង់នៅស្ងៀមហាក់ដូចជាស្រឡាំងកាំងគ្មានវិញ្ញាណ ដោយទ្រង់បានទតឃើញគ្រឿងលម្អ ដែលគេតុបតែងបន្ទប់ស្វាបព្រិលបង្អួច ដែលមានដាំសុទ្ធតែពេជ្រត្បូងទទឹម, ត្បូងមរកតភ្លឺចិញ្ចាចចិញ្ចែងខាងក្នុងក៏ដូចជាខាងក្រៅ ហើយមានទំហំប្រហែល១គ្នា ។ មួយសន្ទុះក្រោយមក ព្រះអង្គក៏មានព្រះបន្ទូលទៅកាន់លោកនាយករដ្ឋមន្ត្រី ដែលឈរនៅក្បែរព្រះអង្គថា : "តើនៅក្នុងនគររបស់ខ្ញុំនេះអាចមានប្រាសាទដ៏ល្អអស្ចារ្យនៅជិតប្រាសាទខ្ញុំ ហើយខ្ញុំឥតបានដឹងដូច្នេះទេ? -ព្រះករុណាថ្លៃវិសេស (លោកនាយករដ្ឋមន្ត្រីឆ្លើយ) សូមព្រះអង្គទ្រង់ព្រះចិន្ដាថា កាលពីម្សិលម៉្ងៃមិញនេះព្រះករុណាទ្រង់អនុញ្ញាតឱ្យអាឡាដាំង ដែលព្រះអង្គទទួលស្គាល់ថាជាព្រះរាជធិតុបតិព្រះអង្គ សង់ប្រាសាទមួយទល់មុខនឹងប្រាសាទព្រះអង្គ ។ នៅថ្ងៃដដែលនោះពេលថ្ងៃជិតលិច នៅត្រង់កន្លែងនេះគេឥតទាន់មានឃើញប្រាសាទនេះឡើយ ។ ទើបតែពីម្សិលមិញនេះ ដូចដែលទូលព្រះបង្គំជាខ្ញុំ បានមកទូលព្រះអង្គមុនគេបង្អស់ថា ប្រាសាទ

នេះសង់រួចស្រេចបាច់ហើយ ។ - ខ្ញុំនឹកឃើញហើយ (ព្រះមហាក្សត្រមានព្រះបន្ទូលតប) ប៉ុន្តែខ្ញុំពុំបាននឹកស្មានដល់ថា ប្រាសាទនេះជាអច្ឆរិយវត្ថុមួយដ៏ល្អវិសេសវិសាលជាងប្រាសាទនានាក្នុងពិភពលោកឡើយ ។ តើនៅក្នុងសាកលលោកនេះ នរណាអាចឃើញមានប្រាសាទ ឯណាមួយដែលជើងជញ្ជាំងធ្វើសុទ្ធតែអពីមាស និងប្រាក់ទាំងដុល។, រនាំងឈើនៅគ្រប់បង្អួចស្រោបសុទ្ធតែពេជ្រ ត្បូងទទឹម ត្បូងមរកត? គ្មានសោះហើយៗនៅនាលោកយើងនេះ, របស់ដ៏ល្អអស្ចារ្យដូច្នេះ!" ។

ព្រះបាទស៊ុលតង់ ប្រុងនឹងយាងទតមើល លម្អនៃរនាំងបង្អួចគ្រប់ទាំង២៤, ប៉ុន្តែលុះរាប់ទៅព្រះអង្គទ្រង់ទតឃើញរនាំង ២៣ មានលម្អប្រហែលគ្នាទាំងអស់, នៅសល់តែរនាំងទី២៤ ពុំទាន់ធ្វើហើយ ជាហេតុនាំឱ្យព្រះអង្គទ្រង់ងឿងឆ្ងល់ជាក្រៃលែង ទើបទ្រង់ត្រាស់សួរទៅលោកនាយករដ្ឋមន្ត្រីដែលនៅក្បែរព្រះអង្គជានិច្ចថា ខ្ញុំឆ្ងល់ណាស់បន្ទប់ដ៏ល្អក្រៃលែងដូច្នេះ ហើយនៅមានសល់តែកន្លែងមួយបន្តិចដូច្នេះ ធ្វើពុំទាន់ហើយ ។ - សូមទូលព្រះករុណាថ្លៃវិសេស (លោកនាយកឆ្លើយ) ប្រហែលជាអាឡាដាំងប្រញាប់ពេក ហើយពេលវេលាក៏តិច ដើម្បីនឹងធ្វើរនាំងនេះ ឱ្យបានល្អដូចគេ, ប៉ុន្តែគេជឿជាក់ថា អាឡាដាំងនៅមានគ្រឿងមាសប្រាក់គ្រប់គ្រាន់ទុកសម្រាប់ធ្វើរនាំងនេះ, ស្អែកឡើងនៅពេលថ្ងៃរះភ្លាម គេមុខជានឹងចាប់ធ្វើការនេះបង្ហើយពុំខាន ។



អាឡាដាំង ដែលបានដកខ្លួនថយចេញពីព្រះបាទស៊ុលតង់មួយភ្លែត ដើម្បីបង្គាប់ការអ្វីមួយដល់ពួកអ្នកបម្រើ, ក៏ត្រឡប់មកវិញនៅពេលនោះភ្លាម ។ ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលសួរអំពីរឿងនោះភ្លាមដែរថា : "កូនប្រុស ! នេះហើយជាបន្ទប់ទទួលភ្ញៀវមួយ ដ៏វិសេសក្រៃលែង ដែលត្រូវតែបានទទួលសេចក្ដីសរសើរពីជនគ្រប់រូបដែលរស់នៅលើលោកសន្និវាសយើងនេះ" ។ ប៉ុន្តែរបស់មួយដែលធ្វើឱ្យបិតាឆ្ងល់ពេក គឺរនាំងបង្អួចមួយនេះធ្វើពុំទាន់ហើយ តើមកពីការភ្លេចភ្លាំង, មកពីការប្រហែសធ្វេស ឬដោយហេតុមកពីពួកជាងរកពេលនឹងបង្ហើយការមួយដុំនេះពុំបាន? - ព្រះករុណាថ្លៃវិសេស ! (អាឡាដាំងឆ្លើយ) ការដែលរនាំងបង្អួចនេះ ធ្វើពុំហើយមិនមែនមកពីរឿងដូច្នេះទេ គឺមកពីទូលព្រះបង្គំ មានបំណងទុកថ្វាយព្រះករុណាធ្វើបង្ហើយបន្ទប់ និងប្រាសាទ ដើម្បីជាកិត្តិនាមដល់ព្រះអង្គថា ព្រះអង្គបានកសាងបន្ទប់ និងប្រាសាទនេះ ។ សូមព្រះអង្គទ្រង់ព្រះមេត្តាទទួលតាមសេចក្ដីប៉ងប្រាថ្នារបស់ទូលព្រះបង្គំ ដើម្បីទុកជាទីរលឹកដល់ក្ដីអនុគ្រោះ និងទឹកព្រះទ័យដ៏ទោរទន់ ដែលព្រះអង្គបានធ្វើដល់ទូលព្រះបង្គំ ។ ព្រះបាទស៊ុលតង់ ក៏ទ្រង់មានព្រះបន្ទូលតបវិញថា : "បើសិនជាកូនឯងមានបំណងដូច្នេះមែន បិតាអស់មានការងឿងឆ្ងល់ហើយបន្តិចទៀតខ្ញុំនឹងបង្គាប់ឱ្យពួកជាងមកបង្ហើយការនេះ" ។ មានព្រះបន្ទូលដូច្នោះហើយ ព្រះនរបតីក៏ទ្រង់បង្គាប់ឱ្យគេហៅពួកជាងច្នៃត្បូង

ដែលមានត្បូងច្រើនជាងគេ និងពួកជាងទងយ៉ាងជំនាញៗនៅក្នុងព្រះរាជធានីឱ្យចូលមកគាល់ព្រះអង្គ ។

នៅពេលនោះ, ព្រះបាទស៊ុលតង់ ក៏យាងចេញពីបន្ទប់ទទួលភ្ញៀវ, អាឡាដាំង ក៏នាំព្រះអង្គចូលទៅក្នុងបន្ទប់មួយទៀត ដែលអ្នកបានរៀបចំជប់លៀងព្រះអង្គម្ចាស់បាឌ្រូលប៊ូឌួរ នៅថ្ងៃរៀបអភិសេក។ ក្រោយបន្តិចមក, ព្រះនាងក៏យាងចេញមកទទួលព្រះបាទស៊ុលតង់ជាព្រះបិតាប្រកបដោយទឹកព្រះភក្ត្រដែលធ្វើឱ្យព្រះបិតា ទ្រង់ជ្រាបថា នាងមានសេចក្ដីសោមនស្សរីករាយជាក្រៃលែងក្នុងការរៀបអភិសេកឱ្យមានគូស្វាមីនេះ ។ នៅក្នុងបន្ទប់នោះមានតុពីរដាក់ សុទ្ធតែម្ហូបអាហារពោរពេញ, ហើយរបស់ដែលសម្រាប់ប្រើប្រាស់មានចានក្បានជាដើមសុទ្ធតែធ្វើអំពីមាស ។ ព្រះបាទស៊ុលតង់ក៏ទ្រង់យាងទៅកាន់តុមួយមុនគេ រួចចាប់សោយក្រយាស្ងោយនេះជាមួយនឹងព្រះរាជបុត្រី, អាឡាដាំងជាមួយនឹងលោកនាយករដ្ឋមន្ត្រី។ បន្ទាប់មកទើបពួកមន្ត្រី ក្នុងវាំងចូលអាស្រ័យនៅតុមួយទៀត ដែលមានបណ្ដោយយ៉ាងវែង ។ ព្រះបាទស៊ុលតង់ទ្រង់សម្គាល់ឃើញម្ហូបអាហារទាំងនេះមានឱជារសឆ្ងាញ់ណាស់។ ព្រះអង្គក៏មានព្រះរាជឱង្ការប្រាប់ថា ព្រះរាជបរិពារព្រះអង្គពុំដែលបានអាស្រ័យម្ហូបអាហារដ៏ ឆ្ងាញ់ពិសាដូច្នេះទេ សូម្បីតែស្រាទំពាំងបាយជូក៏ឆ្ងាញ់រកប្រៀបគ្មាន។ តែរបស់ដែលព្រះអង្គសរសើរជាងគេ គឺទូដាក់ចានក្បានធំៗដែលដាក់សុទ្ធតែ



ដប ថាសនឹងចានទ្រធ្វើអំពីមាសទាំងដុលៗ ។ ឯសូរសម្លេងតូរ្យតន្ត្រីទៀត ក៏ធ្វើឱ្យព្រះអង្គសព្វព្រះទ័យស្រើបស្រាលជាក្រៃលែង ។

នៅពេលព្រះអង្គយាងចេញពីតុភ្លាម គេក៏ក្រាបបង្គំទូលថាពួកជាងថ្មៃត្បូង និងពួកជាងទង ដែលព្រះអង្គទ្រង់ត្រាស់បង្គាប់ឱ្យគេហៅនោះបានមកដល់ហើយ ។ ព្រះអង្គក៏យាងឡើងទៅក្នុងបន្ទប់ទទួលភ្ញៀវ ដែលមានបង្អួច២៤ វិញ ពួកជាងទាំងពីរពួកក៏ឡើងតាម។ លុះទៅដល់, ព្រះអង្គក៏ចង្អុលទៅរនាំងបង្អួច ដែលពុំទាន់ ហើយប្រាប់ពួកជាងព្រមទាំងមានព្រះបន្ទូលថា : “យើងអញ្ជើញជាងឯងមកនេះដើម្បីឱ្យធ្វើរនាំងនេះបង្ហើយ ហើយធ្វើឱ្យបានល្អដូចជារនាំងឯទៀតផង ។ ដូច្នេះ, សូមអញ្ជើញពិនិត្យមើលរនាំងឯទៀត ឱ្យមែនទែន, រួចកុំបង្អង់យូរត្រូវធ្វើរនាំងនេះឱ្យហើយដូចគេឡើង ។

ពួកជាងថ្មៃត្បូង និងពួកជាងទងក៏ចូលទៅពិនិត្យមើលរនាំងទាំង២៣ នោះយ៉ាងម៉ត់ចត់ ។ លុះបានពិនិត្យសព្វគ្រប់ទាំងអស់គ្នាទៅ, ពួកជាងក៏ត្រឡប់មកក្រាបថ្វាយបង្គំព្រះបាទស៊ុលតង់វិញ, ជាងថ្មៃត្បូងនៅក្នុងព្រះបរមរាជវាំងក៏ទូលតាមជាងឯទៀតឡើងថា: “សូមក្រាបបង្គំទូលព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាប្រុងប្រៀបជាស្រេចថា នឹងចំណាយធនធាននិងបញ្ញា ដែលមានទាំងប៉ុន្មាន ដើម្បីធ្វើការនេះ ឱ្យបានសម្រេចតាមព្រះរាជបំណង ប៉ុន្តែតាំងពីទូលព្រះបង្គំ យើងខ្ញុំរកស៊ីប្រកបរបរនេះមក ទូលព្រះបង្គំ

យើងខ្ញុំពុំដែលមានត្បូងថ្ម ដ៏មានតម្លៃក្រៃលែង ហើយច្រើនគ្រប់គ្រាន់ ដល់យកទៅប្រើការដូច្នេះបានឡើយ ។ យើងមាន. ព្រះបាទស៊ុលតង់ មានបន្ទូល យើងមានច្រើនហួសពីសេចក្តីត្រូវការនេះទៅទៀត ចូរអ្នក ទៅប្រាសាទយើងៗ និងយកមកឱ្យអ្នកមើល ស្រេចតែនឹងអ្នករើស យកតាមត្រូវការចុះ" ។

លុះព្រះបាទស៊ុលតង់យាងត្រឡប់ទៅដល់ប្រាសាទវិញ. ព្រះ អង្គក៏ទ្រង់មានព្រះរាជបង្គាប់ឱ្យគេរើយកមាសប្រាក់ ចេញពីឃ្លាំង មក. ពួកជាងច្នៃត្បូងក៏ប្រមូលយកគ្រឿងអលង្ការទាំងនោះជាច្រើន ពិសេស គឺយកតែគ្រឿងមាស ដែលជាដង្វាយរបស់អាឡាដាំង ទៅ ប្រើការធ្វើរនាំងបង្អួចនោះ ប៉ុន្តែអស់ចំនួនមួយខែគត់ហើយ ពួកជាង ទាំងនោះធ្វើរនាំងបង្អួចនោះឥតទាន់ហើយ សូម្បីតែពាក់កណ្តាលក៏ ទេដែរ ឯគ្រឿងមាសប្រាក់ព្រះបាទស៊ុលតង់ក៏អស់ធ្វើពុំគ្រាន់. ដូច្នេះ ព្រះអង្គ ក៏ខ្ចីគ្រឿងមាសប្រាក់ពួកជាងមកបង្គ្រប់ទៀត ។ អាស្រ័យនូវ ការប្រឹងប្រែង ដោយអស់សមត្ថភាពរៀងៗខ្លួន ពួកជាងទាំងនោះ ក៏ បានធ្វើរនាំងបង្អួច ហើយបានពាក់កណ្តាល ។

និទានពីអាឡាដាំង ដែលបានដឹងជាមុនថា ព្រះបាទស៊ុលតង់ ដែលទ្រង់ខំប្រឹងចាត់ចែង ធ្វើរនាំងបង្អួចនេះឱ្យដូចបង្អួចឯទៀតៗនោះ ពិតជាពុំកើតឡើយ ហើយនាំឱ្យតែខាតព្រះកាយពលទៀតផង ទើប ហៅពួកជាងទងទាំងអម្បាលម៉ានមកប្រាប់មិនត្រឹមតែឱ្យឈប់ធ្វើការ



ប៉ុណ្ណោះទេ គឺថែមទាំងបង្គាប់ឱ្យពួកជាងទាំងនោះរុះរនាំងនោះចេញ និងជញ្ជូនយកមាសប្រាក់ណា ដែលជារបស់ព្រះបាទស៊ុលតង់ទៅថ្វាយ ព្រះអង្គវិញ. ឯមាសប្រាក់ណាដែលបានខ្ចីលោកនាយកនោះ ក៏ត្រូវ យកទៅជូនលោកវិញដែរ ។

ការដែលពួកជាងច្នៃត្បូង និងពួកជាងទងបានធ្វើមក ជាង៦ អាទិត្យនោះ ក៏ត្រូវរុះរើចេញភ្លាមមួយរំពេច ។ រួចពួកជាងទាំងឡាយ ក៏ត្រឡប់ទៅវិញអស់ នៅសល់តែអាឡាដាំងម្នាក់ឯងក្នុងបន្ទប់ ។ នៅ ពេលនោះ, អាឡាដាំងក៏ទាញយកចង្កៀង ដែលដាក់នៅត្រង់កន្លែង លើក្បាលដំណេកខ្លួន មកត្រដុសហៅអារក្ស ។ មួយសន្ទុះ អារក្សក៏ មកដល់. អាឡាដាំងក៏និយាយឡើងថា: "កាលពីពេលមុនខ្ញុំបាន បង្គាប់ អ្នកឱ្យទុករនាំងបង្អួចបន្ទប់មួយនេះ កុំអាលធ្វើឱ្យហើយៗអ្នកក៏បាន ធ្វើតាមបង្គាប់ខ្ញុំមែន។ ឥឡូវនេះខ្ញុំហៅអ្នកមកដើម្បីប្រាប់អ្នកថា ខ្ញុំ មានបំណងនឹងឱ្យអ្នកធ្វើរនាំងបង្អួចនេះឱ្យហើយដូចជារនាំងឯទៀតៗ" ។ ឮដូច្នោះ អារក្សក៏អន្តរធានបាត់ទៅ. អាឡាដាំងក៏ចុះពីបន្ទប់មក ក្រោម ។ មួយស្របក់ក្រោយមកវាក៏ឡើងទៅលើបន្ទប់នោះវិញ. ស្រាប់តែឃើញរនាំងបង្អួចនោះ ហើយដូចសេចក្តីប្រាថ្នារបស់ខ្លួនមែន។

ពោលពីពួកជាងច្នៃត្បូងនិងជាងទងវិញ. នៅពេលនោះក៏បាន ចូលទៅដល់ព្រះរាជវាំងព្រះបាទស៊ុលតង់វិញ រួចទៅថ្វាយបង្គំព្រះអង្គ ក្នុងព្រះរាជដំណាក់ ។ ជាងទងម្នាក់ដែលនៅមុខគេ ក៏ថ្វាយគ្រឿង

មាសប្រាក់ ដែលបានរុះរើយកមកពីកន្លែងធ្វើរនាំងបង្អួច. រួចពោលតាងនាមអ្នកទាំងអស់ថា : "បពិត្រព្រះសម្មតិទេព ! ព្រះអង្គទ្រង់ជ្រាបស្រាប់ហើយថា អស់ពេលរវាងប៉ុន្មានហើយ ដែលទូលបង្គំយើងខ្ញុំទាំងអស់គ្នា ខំប្រឹងប្រែងធ្វើការ ដើម្បីនឹងបង្ហើយការ ដែលល្អងធូលីទ្រង់តម្រូវ មកលើរូបទូលព្រះបង្គំទាំងអស់គ្នា ។ ការនោះបានធ្វើជឿនណាស់ទៅហើយ ស្រាប់តែអាឡាដាំងមកប្រាប់ មិនត្រឹមតែឱ្យទូលព្រះបង្គំទាំងអស់គ្នាឈប់ធ្វើការប៉ុណ្ណោះទេគឺថែមទាំងឱ្យទូលព្រះបង្គំយើងខ្ញុំរុះរើរបស់ ដែលបានធ្វើរួចហើយនោះចេញហើយឱ្យនាំយកគ្រឿងមាសប្រាក់ទាំងនោះ មកថ្វាយព្រះអង្គ និងទៅជូនលោកនាយករដ្ឋមន្ត្រីវិញ" ។ ព្រះបាទស៊ុលតង់ទ្រង់ត្រាស់សួរអ្នកទាំងអស់នោះវិញថា តើអាឡាដាំងឥតបាននិយាយហេតុផលប្រាប់អ្នកអំពីរឿងនេះទេឬ? លុះអ្នកទាំងអស់គ្នាទូលតបទៅវិញថា អាឡាដាំងឥតបានបង្ហាញហេតុផលឱ្យឃើញសោះ. ព្រះអង្គក៏ទ្រង់បង្គាប់មួយរំពេចឱ្យគេនាំអាជានេយ្យមួយមកថ្វាយព្រះអង្គ ។ គេក៏ធ្វើតាមបង្គាប់. ព្រះអង្គក៏ទ្រង់ឡើងគង់លើខ្នងពាជីនោះបរចេញ ទៅដោយមានព្រះរាជបរិពារ ដែលនៅគាល់បម្រើព្រះអង្គផ្ទាល់ហែហមទៅជាមួយផងប៉ុន្តែឥតមានជិះអ្វីឡើយ ។ យាងទៅដល់ប្រាសាទអាឡាដាំងព្រះអង្គក៏ទ្រង់ចុះត្រង់មាត់ជណ្តើរទៅកាន់បន្ទប់ ដែលមានបង្អួច២៤ រួចយាងឡើងទៅក្នុងបន្ទប់ ដោយឥតមានប្រាប់អាឡាដាំងឱ្យដឹងជាមុនបន្តិច



សោះ ប៉ុន្តែពេលនោះ អាឡាដាំង ក៏នៅក្នុងបន្ទប់នោះស្រាប់ ហើយចេញមកទទួលព្រះអង្គទាន់ ត្រឹមតែមាត់ទ្វារបន្ទប់ប៉ុណ្ណោះ ។

ព្រះបាទស៊ុលតង់ ដើម្បីកុំឱ្យអាឡាដាំងតូចចិត្តនិងព្រះអង្គទាន់ អំពីការដែលព្រះអង្គយាងមក ដោយឥតបានឱ្យដំណឹងនិងការធ្វើឱ្យរំខានដល់អាឡាដាំង ក៏ទ្រង់មានបន្ទូលភ្លាមឡើងថា: "កូនប្រុស ! ការដែលបិតាមកផ្ទាល់ខ្លួនតែម្តងនេះ ដើម្បីសួរឯងឱ្យដឹង តើឯងយល់ឃើញដូចម្តេច បានជាឯងពេញចិត្តនឹងទុកបន្ទប់ទទួលភ្ញៀវដ៏ល្អលើសលប់ក្រៃលែង ជាងប្រាសាទឯងទៅទៀត ឱ្យសល់នៅពុំទាន់ហើយសព្វគ្រប់ដូច្នេះ" ។

អាឡាដាំងមិនហ៊ានទូលព្រះអង្គ តាមហេតុផលពិតប្រាកដនោះឡើយ ការពិតគឺអាឡាដាំងចង់លើកកំពស់ខ្លួនឯងថា ព្រះបាទស៊ុលតង់ពុំអាចមានមាសប្រាក់គ្រប់គ្រាន់ ដើម្បីយកមកចំណាយធ្វើការនេះឡើយ ។ ប៉ុន្តែដើម្បីឱ្យព្រះអង្គជ្រាបច្បាស់ថា តើប្រាសាទនេះមានលម្អយ៉ាងណានោះ គឺថាមិនត្រឹមតែល្អដាច់ប្រាសាទ ព្រះបាទស៊ុលតង់ប៉ុណ្ណោះទេ សូម្បីតែប្រាសាទនានាក្នុងលោក ក៏គ្មានប្រដូចបានសោះឡើយ. ព្រោះព្រះអង្គ ដែលជាមហាក្សត្រមួយទាំងមូល ក៏សូម្បីតែបង្ហើយតួប្រាសាទត្រង់ណាបន្តិចក៏ពុំកើតផង. ទើបអាឡាដាំងទូលតបទៅវិញថា: "សូមទូលព្រះករុណាថ្លៃវិសេស. គឺពិតដូច្នេះមែន. ដែលព្រះអង្គទ្រង់បានទតឃើញថាបន្ទប់នោះ ពុំទាន់ហើយ

ដោយសព្វគ្រប់ ប៉ុន្តែក្នុងពេលឥឡូវនេះ ទូលព្រះបង្គំសូមយាងព្រះអង្គទតមើលបន្ទប់នោះម្តងទៀត តើនៅមានខ្វះអ្វីត្រង់កន្លែងណាខ្លះ?" ។

ព្រះបាទស៊ុលតង់ ក៏ទ្រង់យាងសំដៅទៅត្រង់បង្អួច ដែលមានវនាំងធ្វើពុំទាន់ហើយនោះមួយរំពេច។ លុះទៅដល់ទ្រង់ទតឃើញកន្លែងនោះបានធ្វើហើយ ដូចជាកន្លែងឯទៀតទាំងអស់ ក៏ទ្រង់ព្រះចិន្តាថាប្រហែលជាព្រះអង្គច្រឡំបង្អួចហើយ ។ ដូច្នេះ ទ្រង់ក៏ខំសង្កេតមើលមិនត្រឹមតែបង្អួចពីរ ដែលនៅសងខាងបង្អួចនោះទេ គឺទ្រង់ពិនិត្យមួយម្តងៗគ្រប់បង្អួចទាំងអស់ ។ លុះពិនិត្យទៅ ទ្រង់ជ្រាបថា វនាំងបង្អួចដែលទ្រង់បានចំណាយពេលនិងថ្លៃឈ្នួលជាង អស់ជាច្រើនបំផុតនោះបានធ្វើហើយស្រេចក្នុងពេលដ៏ខ្លីបំផុតដូច្នេះ ព្រះអង្គក៏ស្ទុះទៅឱបរឹតអាឡាដាំង រួចទ្រង់ថើបត្រង់កន្លែងប្រជុំចិញ្ចើមព្រមទាំងមានព្រះរាជឱង្ការ ដោយងឿងឆ្ងល់ថា : "កូនប្រុស ! តើឯងជាមនុស្សអ្វី បានជាចេះធ្វើរបស់យ៉ាងប្លែកអស្ចារ្យដូច្នេះ ហើយស្រេចក្នុងពេលតែមួយក្រលៀសភ្នែកដូច្នេះ? គ្មាននរណាមួយក្នុងលោកអាចប្រដូចនឹងអ្នកបានឡើយ ហើយល្អិតណាបិតាបានស្គាល់ឯងកាន់តែជិតស្និទ្ធទៅល្អិតនោះបិតាក៏កាន់តែឃើញឯងល្អឡើងៗដែរ" ។

អាឡាដាំងទទួលអបអរសាទរ នឹងសេចក្តីសរសើរ នៃព្រះបាទស៊ុលតង់ ដោយដាក់ឫកពាចរិយាសុភាពរាបសាជាទីបំផុត រួចក៏ពោលទៅកាន់ព្រះអង្គដោយវាចាដូចតទៅនេះ "ព្រះករុណាថ្លៃវិសេសនេះគឺជាកិត្តិគុណមួយយ៉ាងធំសម្បើមអស្ចារ្យ ចំពោះរូបទូលព្រះបង្គំដែលត្រូវបានទទួលមេត្តាចិត្ត និងសេចក្តីសរសើរពីព្រះអង្គ ។ ការដែលទូលព្រះបង្គំ អាចធានាអះអាងថ្វាយព្រះអង្គបានគឺថា ទូលព្រះបង្គំឥតភ្លេចសោះឡើយ នឹងធ្វើខ្លួនឱ្យសមនិងត្រូវបានទទួលសេចក្តីអនុគ្រោះណាមួយក្នុងបណ្តាសេចក្តីសរសើរទាំងពីរយ៉ាងនេះ" ។



ព្រះបាទស៊ុលតង់ ក៏យាងត្រឡប់ទៅប្រាសាទវិញដោយមានអ្នកហែហមដដែល ដូចកាលដែលព្រះអង្គយាងមកដែរ។ ទ្រង់មិនព្រមអនុញ្ញាតឱ្យអាឡាដាំងហែព្រះអង្គទៅផងឡើយ ។ យាងមកដល់ប្រាសាទវិញ. ព្រះអង្គក៏ទ្រង់ទតឃើញលោកនាយករដ្ឋមន្ត្រីនៅរង់ចាំព្រះអង្គ ។ ព្រះបាទស៊ុលតង់ពោរពេញព្រះទ័យ ទៅដោយការកោតសរសើរដល់អច្ឆរិយវត្ថុ ដែលទ្រង់ជាសាក្សីនៃការឃើញនោះស្រាប់ ក៏ទ្រង់មានព្រះរាជឱង្ការរៀបរាប់ប្រាប់លោកនាយករដ្ឋមន្ត្រី ដោយសព្វគ្រប់ ។ ព្រះរាជបន្ទូលនោះ ឥតធ្វើឱ្យលោកនាយករដ្ឋមន្ត្រីសង្ស័យថារបស់នោះមិនមែនមិនល្អដូចព្រះអង្គមានព្រះបន្ទូលនោះទេ. ប៉ុន្តែព្រះរាជបន្ទូលនោះរឹតតែធ្វើឱ្យលោកនាយករដ្ឋមន្ត្រី ដែលមានជំនឿស្រាប់មកហើយផង កាន់តែចូលចិត្តថា ប្រាសាទនេះពិតជាកើតឡើងដោយសារមន្តអាគម ។ ជំនឿនេះលោកបានទូលព្រះបាទស៊ុលតង់តាំងតែពីឃើញប្រាសាទនោះកើតឡើងភ្លាម ។ ដូច្នេះលោកនាយករដ្ឋមន្ត្រីប្រុងនិយាយរឿងដដែលនេះ ទូលព្រះបាទស៊ុលតង់ទៀត តែ

ព្រះអង្គទ្រង់មានព្រះបន្ទូលកាត់មុនថា: “លោកនាយក ! លោកចង់មានប្រសាសន៍តែពីរឿងដដែលប្រាប់ខ្ញុំទៀត ! ប៉ុន្តែខ្ញុំក៏យល់ដែរថា លោកក៏ពុំទាន់ភ្លេចនៅឡើយទេ អំពីរឿងរៀបអភិសេកបុត្រី ខ្ញុំនឹងកូនប្រុសលោក”។

លោកនាយករដ្ឋមន្ត្រី កាលបើដឹងថាព្រះបាទស៊ុលតង់ ក៏ទ្រង់បានជ្រាបអំពីរឿងនេះដែរ, លោកក៏ឈប់សន្ទនាជាមួយនឹងព្រះអង្គតទៅទៀត ! ទុកឱ្យព្រះអង្គទ្រង់ស្ថិតនៅក្នុងព្រះរាជយោបល់ដូច្នេះចុះ។ រៀងរាល់ថ្ងៃ, ជាទៀងទាត់ នៅពេលដែលព្រះបាទស៊ុលតង់ទ្រង់តើនឡើង, ព្រះអង្គឥតដែលខានយាងឡើងទៅគង់លើបន្ទប់មួយខ្ពស់, ដែលអាចទតទៅឃើញប្រាសាទអាឡាដាំងទាំងមូល ! មិនត្រឹមតែទតពីចម្ងាយដូច្នោះ ព្រះអង្គទ្រង់ថែមទាំងយាងជាច្រើនដងនៅវេលាថ្ងៃៗ ទៅទតនឹងសរសើរប្រាសាទនោះទៀត ។

ពោលពីអាឡាដាំងវិញ អ្នកពុំសូវនៅក្នុងប្រាសាទជាប់មួយកន្លែងឡើយ អ្នកតែងតែដើរកំសាន្តលេងនៅតាមទីក្រុងយ៉ាងហោចណាស់ក្នុងមួយអាទិត្យម្តងដែរ, ជួនកាលទៅសូត្រធម៌ក្នុងព្រះវិហារ ឬនៅកន្លែងដទៃទៀត, ឬក៏យូរៗម្តងអ្នកទៅលេងផ្ទះលោកនាយករដ្ឋមន្ត្រី ដែលបានសំដែងទឹកចិត្តនៅពេលបុរសទៅលេង ហាក់ដូចជាបម្រុងតែនឹងមកលេងផ្ទះអាឡាដាំង នៅថ្ងៃណាមួយដែរ ឬក៏អញ្ជើញទៅលេងផ្ទះលោកមហាសេនាខ្លះ ដែលអ្នកធ្លាប់ទទួលជប់លៀងជាញឹកញយដែរ នៅក្នុងប្រាសាទអ្នក ។ នៅពេលដែលអាឡាដាំងចេញពីវាំងម្តងៗ។ អ្នកតែងបង្គាប់ឱ្យអ្នកបម្រើពីរនាក់ ក្នុងបណ្តាអ្នកបម្រើឯទៀត ដែលដើរនៅជុំវិញសេះឱ្យបាចរូបិយមាសទាំងកំបង់ៗនៅចប់តាមតែផ្លូវនិងតាមកន្លែង ដែលគាត់ធ្វើដំណើរទៅ ហើយនៅគ្រប់កន្លែងណាដែលអាឡាដាំងទៅ នៅគ្រប់តែកន្លែងនោះ គេឃើញប្រជាជនទាំងហ្វូងទាំងហ្វាយមកចោមរោមជានិច្ច ។



ដូច្នេះ គេពុំដែលឃើញជនក្រីក្រណាមួយ ដែលបានទៅដល់មាត់ទ្វារប្រាសាទអាឡាដាំងហើយៗ ត្រឡប់មកវិញដោយឥតសប្បាយចិត្តនឹងអំពើសប្បុរស ដែលអាឡាដាំងបានធ្វើមកលើខ្លួននោះឡើយ ។

ទោះអាឡាដាំង បានចែកពេលវេលាជាស្រេចហើយថា រៀងរាល់សប្តាហ៍ទាំងអស់ គាត់ត្រូវតែទៅបរបាញ់សត្វជានិច្ច, យ៉ាងហោចណាស់ក៏ទៅម្តងក្នុងមួយអាទិត្យដែរ ទោះទៅជិតទីក្រុងក្តីទៅឆ្ងាយៗក្តី ក៏គាត់នៅតែបំពេញអំពើជាកុសលនេះ នៅតាមផ្លូវ និងទៅតាមនិគមជនបទដដែល ។ អាស្រ័យដោយកាយវិការនេះ, គាត់ត្រូវបានទទួលពរសព្ទសាធុការជាច្រើនអនេកពីប្រជាជនផ្សេងៗ នៅទីបំផុតដោយអាឡាដាំង ឥតមានធ្វើព្រះបាទស៊ុលតង់ ដែលគាត់តែងតែចូលទៅ ក្រាបបង្គំគាល់ជានិច្ចជាកាលនោះឱ្យទ្រង់រវល់នឹងកិច្ចការអ្វីសោះ គេអាចសន្និដ្ឋានបានថា ដោយអំណាចកាយវិការទន់ភ្លន់ និងជាបុណ្យ, អាឡាដាំងត្រូវបានប្រជាជនស្រឡាញ់រាប់អានជាច្រើន, គឺប្រជាជន

ស្រឡាញ់អាឡាដាំងជាងព្រះបាទស៊ុលតង់ទៅទៀត ។ គាត់បានខំប្រឹងប្រែងធ្វើការយ៉ាងពេញកម្លាំងខ្លួន ដើម្បីជាប្រយោជន៍ដល់ប្រទេសជាតិ ដែលអ្នកផងពុំសូវដែលនឹកនាសោះ ។ រឿងគិតគូរដល់ប្រយោជន៍ស្រុកទេសនេះ គាត់បានបញ្ចេញឱ្យឃើញភស្តុតាងជាក់ស្តែងរួចមកហើយ នៅពេលមានការរំជើបរំជួលនៅព្រំប្រទល់រួមនៃព្រះរាជាណាចក្រ គឺនៅពេលដែលគាត់ដឹងថា ព្រះបាទស៊ុលតង់ទ្រង់លើកកងទ័ពចេញទៅបង្ក្រាបពួកឧទ្ទាមភ្លាម គាត់ក៏ចូលខ្លួនទៅសូមអង្វរភ្លាមឱ្យទ្រង់អនុញ្ញាតឱ្យគាត់ធ្វើជាមេបញ្ជាការ ។ គាត់ក៏បានទទួលព្រះរាជានុញ្ញាតដោយស្រួល ។ ខណៈដែលគាត់ឡើងកាន់មេបញ្ជាការភ្លាម, គាត់ក៏នាំកងទ័ពចូលសំដៅសម្រុកទៅរកពួកឧទ្ទាមយ៉ាងអង់អាចរហ័សរួសរាន់ជាទីបំផុតមិនយូរប៉ុន្មានព្រះបាទស៊ុលតង់ក៏ទ្រង់ជ្រាបថា ពួកឧទ្ទាមត្រូវបរាជ័យបែកបាក់គ្នាអស់ហើយ ។ កិច្ចប្រតិបត្តិការបានញ៉ាំងឈ្មោះគាត់ ឱ្យលេចឮរន្ទឺពេញ ផ្ទៃព្រះរាជអាណាចក្រ ប៉ុន្តែឥតធ្វើឱ្យគាត់មានចិត្តព្រហើនឡើយ ។ គាត់ត្រឡប់មកវិញមានទឹកមុខប្រកបដោយជ័យជំនះ ហើយនិងចិត្តទន់ភ្លន់សុភាពរាបសាដដែល ។ អាឡាដាំងបានសោយសម្បត្តិទិព្វនេះអស់ពេលជាច្រើនឆ្នាំហើយ ដូចដែលយើងទើបតែនិទានរួចមកនេះ ទម្រាំតែមេធ្មប់អាហ្វ្រិកាំងនឹកឃើញអំពីរឿងដែលគាត់ស្ទើរតែបំភ្លេចចោលទៅហើយ ។ តែបើទោះណាជាតាំងពីពេលនោះ រហូតមកដល់ពេលឥឡូវនេះមេធ្មប់



ជឿជាក់ថា អាឡាដាំងស្លាប់ដោយវេទនានៅក្នុងរូង ដែលគាត់សន្ធប់ថ្មនោះហើយក៏ដោយ ក៏ស្រាប់តែពេលនេះ កើតមានគំនិតមួយនាំឱ្យគាត់ចង់ដឹងពិតប្រាកដ នូវទីបំផុតនៃរឿងអាឡាដាំង ។ ដោយគាត់ជាអ្នកហោរាសាស្ត្រមួយយ៉ាងធំទៀតផង, គាត់ក៏ទាញយកពីក្នុងទូនូវកំណាត់ឈើបួនជ្រុងស្មើ មានរាងដូចជាប្រអប់បិទគ្របមកគន់គូរមើល គាត់អង្គុយនៅលើកៅអីវែងយកឈើបួនជ្រុងស្មើដាក់ពីមុខរួចក៏បើកមើល ។ លុះក្រោយពីបែងចែកគ្រាប់ខ្សាច់ជាភាគស្មើគ្នាដោយមានបំណងចង់ដឹងថា តើអាឡាដាំងស្លាប់នៅក្នុងរូងក្នុងដីឬ? គាត់ក៏បាចគ្រាប់ខ្សាច់នោះ ខាបទៅជាមុខមនុស្សរួចក៏ទាយ ។ លុះពិនិត្យគន់គូរលេខអត្ថៈចំត្រង់កន្លែងរូបនោះទៅ មេធ្មប់ក៏ដឹងថា អាឡាដាំងចេញរួចពីកន្លែងនោះហើយ១សព្វថ្ងៃ រស់នៅក្នុងកន្លែងដ៏រុងរឿង, ខ្ពង់ខ្ពស់សម្បូណ៌ទ្រព្យសម្បត្តិហូរហៀរ រាប់ពុំអស់ត្រូវជាស្វាមីនៃម្ចាស់ក្សត្រីមួយព្រះអង្គ, ដែលទ្រង់ស្រឡាញ់នឹងគោរពកោតខ្លាចអាឡាដាំងជាខ្លាំងទៀតផង ។

មេធ្មប់អាហ្វ្រិកាំង កាលបើបានដឹងដំណឹងនេះភ្លាម, ដោយសារសិល្បៈទំនាយរបស់គាត់ថា អាឡាដាំងរស់នៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់ដូច្នេះ ភ្លើងទោសៈក៏ឆាបឆេះមុខគាត់ឡើងក្រហម ។ គាត់ក៏អន្ទះអន្ទែងក្នុងខ្លួនដូចព្រាយក្បាលប្រាំបីចូលលែងដឹងខុសត្រូវនិយាយតែឯងថា : "អាកូនកម្សត់នៃជាងកាត់ខោអាវនេះ វាបានរកឃើញការ

សម្ងាត់និង គុណធម៌នៃចង្កៀងនោះហើយអញបាននឹកស្មានថា វាស្លាប់ទៅហើយ ឥឡូវនេះស្រាប់តែរស់នៅយ៉ាងសប្បាយដោយសារកិច្ចការ និងចំណេះវិជ្ជារបស់អញ ដែលអញខំសំភីរកមកដូច្នេះអញនឹងប្រញាប់ទៅបំផ្លាញវា ដើម្បីកុំឱ្យវាបានសប្បាយយូរពេក ឬមួយអញនឹងបំបាត់ក្បាលវាឱ្យវិនាសសាបសូន្យតែម្តង" ។ គិតដូច្នេះមិនយូរប៉ុន្មានព្រឹកស្អែកឡើងមេធ្មប់ក៏ជិះសេះមួយ ដែលមាននៅក្នុងរោងសេះរបស់គាត់ស្រាប់ធ្វើដំណើរចេញទៅ ឆ្លងពីទីក្រុងមួយទៅទីក្រុងមួយពីខេត្តមួយទៅខេត្តមួយ ឈប់សម្រាកខ្លះកុំឱ្យតែអស់កម្លាំងខ្លាំងពេក. លុះត្រាតែទៅដល់អាណាចក្រចិន. ហើយក៏ចូលទៅក្នុងព្រះរាជធានីនៃព្រះបាទ

ស្អែកឡើងគ្រូធ្មប់អាហ្វ្រិកចាប់ផ្តើមស្ទាបស្ទង់មើល តើអ្នកផងទាំងឡាយនិយាយពីអាឡាដាំងយ៉ាងម៉េចខ្លះ ។ គាត់ដើរយឺតៗតាមផ្លូវតូចធំ។ រួចចុងក្រោយឆ្លៀតចូលតំបន់ដែលល្បីឈ្មោះខាងស្រាកំដៅ។ នៅទីនោះតាមគាត់ធ្លាប់ដឹងគឺសម្បូរអភិជននិងពួកអ្នកមានជួបជុំគ្នាប្រាជ្ញប្រែពាកវាល់ល្ងាច ។ គាត់ផឹកស្រាកំដៅដែរ, ផឹកផងយកចិត្តទុកដាក់ស្តាប់គេនិយាយគ្នាផង ឮភាគច្រើនរំលឹករឿងវិមានអាឡាដាំង ជាមួយអាការៈកោតសរសើរ ។ លុះផឹករួចគាត់សសៀរទៅជិតបុរសម្នាក់ សួរនាំពីវិមានបុត្រប្រសារស្តេច តើស្អាតយ៉ាងម៉េចខ្លះ ។ «អ្ហា, អឹងឯងមកពីណាបានជាសួរអ៊ីចឹង? (បុរសនោះបើកភ្នែកធំៗឆ្លើយវិញ) នៅរាជធានីនេះ សូម្បីកូនក្មេងក៏ធ្លាប់ឃើញដែរ ។ បើអឹពិតជាមិនដឹងមែនចាំខ្ញុំប្រាប់, វិមានរបស់បុត្រប្រសាព្រះរាជាជាអច្ឆរិយវត្ថុលេខមួយលើផែនដី, គ្មានអច្ឆរិយវត្ថុណាអាចប្រៀបផ្ទឹមបាន។ អឹគួរឆ្លៀតទៅមើលនឹងគេកុំឱ្យស្តាយក្រោយ, ទៅដល់មុខវាំងឃើញហើយ» ។

ដឹងត្រឹមប៉ុណ្ណោះ គ្រូធ្មប់អាហ្វ្រិកម្ចីម្នាថ្លែងអំណរគុណអ្នកប្រាប់រួចចេញពីកន្លែងផឹកស្រា ។ ពេលទៅដល់គោលដៅ គាត់ក្រឡឹងវិមាន

អាឡាដាំងពីរបីជុំ ពិនិត្យសង្កេតអត់ឱ្យសល់ចំណុចណាមួយ ។ ភាពអស្ចារ្យរបស់វិមានធ្វើឱ្យគាត់កាន់តែជឿថា អាឡាដាំងប្រើប្រាស់ចង្កៀងទិព្វដើម្បីឈានឡើង ។ បញ្ហាជាបឋមគឺធ្វើម៉េចដឹងចង្កៀងទិព្វកំពុងនៅកន្លែងណា, នៅជាប់ក្នុងខ្លួនអាឡាដាំង ឬលាក់ទុកក្នុងវិមាន? កិច្ចការនេះទាល់តែអនុវត្តវេទមន្តប្រមើលមើល ។

គ្រូធ្មប់អាហ្វ្រិកប្រញាប់ប្រញាល់ត្រឡប់មកកន្លែងវិញ យកសម្ភារៈចេញដើម្បីធ្វើការប្រមើលមើល ។ ឆ្លងកាត់បែបផែនអាថិកំបាំងប្រហែលកន្លះម៉ោង គាត់ដឹងច្បាស់ថា ចង្កៀងទិព្វកំពុងនៅក្នុងវិមាន ។ គាត់ត្រេកអរហៅកញ្ជ្រៀវស្វាត់ៗម្នាក់ឯង :

- តែប៉ុណ្ណេះបានការហើយ, យើងនឹងរកមធ្យោបាយយកចង្កៀងទិព្វឱ្យទាល់តែបាន ។ ដល់ពេលនោះយើងនឹងក្លាយជាមនុស្សអស្ចារ្យលើផែនដី ចំណែកអាឡាដាំងត្រូវតែវិលទៅរកឋានៈថោកទាបរបស់វាវិញ ។

ជាប្រការអភ័ព្វសម្លាប់អាឡាដាំង, នារយៈពេលគ្រូធ្មប់អាហ្វ្រិកកំពុងមានផែនការពិសពុល នាយបែរជាមានគម្រោងចេញទៅបរបាញ់រហូតដល់ប្រាំបីថ្ងៃ យូរជាងសព្វដង ឥឡូវទើបតែបានបីថ្ងៃប៉ុណ្ណោះ ។ គ្រូធ្មប់អាហ្វ្រិកដឹងប្រការនេះច្បាស់ណាស់ គឺដឹងដោយសាស្ទាបស្ទង់មេការក្នុងផ្ទះសំណាក់ ។ ដំបូងគាត់នាំអាទីនិយាយលេង រួចធ្វើជាអួតថា អម្បាញ់មិញខ្លួនបានទៅមើលវិមានរបស់បុត្រប្រសាស្តេច វិមាន



នោះពិតជាអច្ឆរិយវត្ថុអស្ចារ្យលើផែនដីមែន ប៉ុន្តែគាត់មិនទាន់អស់ចិត្ត ដោយឥតបានឃើញមុខម្ចាស់វិមានដោយផ្ទាល់ ។ ឮដូច្នេះមេការផ្ទះសំណាក់តប :

- គ្មានអ្វីពិបាកឃើញមុខតេជគុណអាឡាដាំងទេ, គាត់ឧស្សាហ៍ដើរកំសាន្តតាមផ្លូវនានា យ៉ាងយូរពីរបីថ្ងៃដើរម្តង, ទាស់តែបីថ្ងៃកន្លងមកនេះគាត់ជាប់ទៅបរបាញ់ឆ្ងាយ ឮថាទាល់តែប្រាំថ្ងៃទៀតទើបត្រឡប់មកវិញ ។

ដឹងត្រឹមប៉ុណ្ណេះគ្រប់គ្រាន់ពេកហើយ, គ្រូធ្មប់អាហ្វ្រិកលាមេការផ្ទះសំណាក់ ដើរសំដៅទៅផ្សារ ដើរបណ្តើរនិយាយបណ្តើរ :

- នេះជាឱកាសល្អបំផុត, កុំបណ្តោយឱ្យកន្លងហួសបាន !

គាត់ចូលក្នុងហាងមួយដែលជំនាញខាងផលិតចង្កៀង, សួរម្ចាស់ហាង :

- ខ្ញុំត្រូវការចង្កៀងស្អាតមួយឡូ, លោកបងមានគ្រប់ទេ ?

ម្ចាស់ហាងឆ្លើយថាខ្វះពីរបី បើទ្រាំចាំបានដល់ព្រឹកស្អែកនឹងមានគ្រប់ចំនួន ។ គ្រូធ្មប់អាហ្វ្រិកយល់ព្រម តែដាក់លក្ខខណ្ឌចង្កៀងទាំងអស់ត្រូវដុសខាត់ឱ្យភ្លឺរលោងឃើញគួរស្រឡាញ់ ។

ព្រឹកឡើងម្ចាស់ហាងប្រគល់ចង្កៀងគ្រប់មួយឡូតាមការតម្រូវរបស់ភ្ញៀវ, ចង្កៀងសុទ្ធតែថ្មីច្រើង ។ គ្រូធ្មប់អាហ្វ្រិកប្រមូលដាក់ចូលកញ្ចើមួយដែលយកតាមខ្លួនហើយស្រេច ។ គាត់កណ្តៀតកញ្ចើនោះ

ដើរទៅខាងវិមានអាឡាដាំង ទៅជិតដល់ចាប់ផ្ដើមស្រែកពពាយនាយ

- មានចង្កៀងចាស់ ចង់ដូរយកចង្កៀងថ្មីទេ?

ពួកក្មេងកំពុងរត់លេងតាមផ្លូវ ឃើញតាចាស់កណ្ដៀតសុទ្ធតែចង្កៀងថ្មីស្រែកប្រកាសដូរយកចង្កៀងចាស់ ក៏រោមមើលដូចរោមមនុស្សឆ្កួត ។ ទាំងអ្នកដំណើរធម្មតា ក៏លាន់មាត់ដោយហួសចិត្ត :

- យីអើ ! តាចាស់នេះឆ្កួតស៊ុបមែនទែនហើយតើ !

គ្រូធ្មប់អាហ្វ្រិកធ្វើមិនដឹងមិនឮចំពោះការសើចចំអកនេះ គិតតែបន្តស្រែកពពាយនាយ :

- មានចង្កៀងចាស់ ចង់ដូរយកចង្កៀងថ្មីទេ?

គាត់ដើរកាត់ខាងមុខវិមានអាឡាដាំង ដើរផុតមួយសន្ទុះបកមកវិញពពាយនាយដដែលទៀត ធ្វើឱ្យរាជធីតាបាឌ្រូនប៊ូឌូ ដែលកំពុងគង់កំសាន្តនៅសាលទទួលភ្ញៀវចេះតែនឹកឆ្ងល់ពុំដឹងមានរឿងអីបានជាក្មេងពពាក់ពពូនហោកញ្ជ្រៀវខ្លាំងឡើងៗ ។ ទីបំផុតព្រះនាងទ្រាំមិនបានក៏ប្រើទាសីម្នាក់ឱ្យចុះទៅមើល ។

ទាសីរបស់រាជធីតាចេញដល់ផ្លូវធំក៏បកវិញ ដើរបណ្ដើរសើចក្អៀកបណ្ដើរ មកដល់ខាងមុខរាជធីតាទៅហើយនៅតែទប់សំណើចមិនទាន់បាន ។ ឃើញដូច្នេះរាជធីតាគំហក :

- សើចអីហ្នឹង? មានរឿងយ៉ាងម៉េច?

ទាសីខំទប់ខ្លួនទូលថ្វាយ :



- ព្រះនាងអើយ, មនុស្សឆ្កួតល្អមើលណាស់ ។ គេឆ្កួតដើរសើចដើរច្រៀង គាត់នោះឆ្កួតដើរលក់ចង្កៀង តែមិនលក់យកលុយបែរជាពពាយនាយដូរចង្កៀងថ្មីច្រើងយកចង្កៀងចាស់ទៅវិញ ។ សូម្បីក្មេងតូចក៏ហួសចិត្តដែរ, អ៊ីចឹងហើយបានជាក្មេងតាមចោមរោមចំអកគាត់ចប់តាមផ្លូវ ។

ឮដូច្នេះ ទាសីម្នាក់ទៀតស្នើឡើង :

ក្នុងវិមានយើងមានចង្កៀងកញ្ចាស់មួយ ពុំដឹងរបស់អ្នកណាដាក់ចោលលើចុងសសរយូរថ្ងៃហើយ ។ នាងខ្ញុំជឿថាម្ចាស់របស់វាមុខតែពេញចិត្ត ប្រសិនបើយើងដូរយកចង្កៀងថ្មីឱ្យគេ។ បើព្រះនាងយល់អ៊ីចឹងដែរ, យើងសាកល្បងយកចង្កៀងនោះទៅដូរជាមួយតាចាស់ចម្លែកមើល តើគាត់ឆ្កួតមែនឬមិនមែន ។ តាំងពីកើតរហូតដល់អាយុប៉ុណ្ណេះនាងខ្ញុំម្ចាស់ទើបតែឃើញមានមនុស្សយកចង្កៀងថ្មីពពាយនាយ ដូរចង្កៀងចាស់ ដោយអត់ទាមទារថែមលុយ ។

តាមពិត ចង្កៀងដែលទាសីរូបនោះនិយាយ គឺចង្កៀងទិព្វដែលបានជួយឱ្យអាឡាដាំងមានឋានៈខ្ពង់ខ្ពស់ ។ នាយតែងយកឡើងដាក់លើចុងសសររាល់ពេលត្រូវការធ្វើដំណើរទៅឆ្ងាយ, ប៉ុន្តែទាំងរាជធីតាទាំងទាសីរបស់ព្រះនាងអត់នរណាដឹងឡើយ ។

រាជធីតាបាឌ្រូប៊ូឌូមិននឹកស្មានថា ចង្កៀងលើចុងសសរជាវត្ថុសក្តិសិទ្ធពាក់ព័ន្ធដល់អាយុជីវិតអាឡាដាំងនិងព្រះនាងផ្ទាល់, ឮដូច្នេះ

នឹកចង់កំប្លែងលេងក៏ប្រើទាសករម្នាក់ឡើងយកចុះ ហើយប្រាប់ឱ្យយកទៅដូរសាកមើល តើគេដូរមែនឬមិនមែន ។ ទាសកររូបនោះកាន់ចង្កៀងដើរទៅខាងផ្លូវធំ លើកបង្ហាញគ្រូធ្មប់អាហ្វ្រិក :

- ដូរជាមួយចង្កៀងនេះទេ, លោកតា ?

គ្រូធ្មប់អាហ្វ្រិកស្រក់ទឹកមាត់នៅពេលក្រឡេកឃើញចង្កៀងកញ្ចាស់លើដៃទាសករ ។ គាត់ជឿថានេះពិតជារបស់សក្តិសិទ្ធិដែលគាត់ត្រូវការបំផុត, ក្នុងវិមានមួយដែលអ្វីៗក៏ធ្វើពីមាសប្រាក់ ពុំអាចមានចង្កៀងកញ្ចាស់បែបនេះឡើយ ។ គាត់ងក់ក្បាលទទួលចង្កៀងកញ្ចាស់ញាត់លាក់ក្នុងអាវ ហើយចង្អុលចង្កៀងថ្មីមួយឡូក្នុងកញ្ជើ ប្រាប់ទាសករនោះឱ្យជ្រើសរើសយកខ្លួនឯងតាមការស្រឡាញ់ ។ ទាសកររូបនោះ ក៏ជ្រើសចង្កៀងថ្មីមួយដែលខ្លួនពេញចិត្តជាងគេ យកទៅថ្វាយរាជធីតាបាឌ្រូនប៊ូឌូ ។ ការដូរដោះនោះប្រព្រឹត្តទៅជាសាធារណៈកណ្តាលវាល បណ្តាលឱ្យពួកក្មេងកាន់តែហោកញ្ជ្រៀវចំអកគ្រូធ្មប់អាហ្វ្រិក ។ ប៉ុន្តែគ្រូធ្មប់អាហ្វ្រិកធ្វើព្រងើយ អត់ខ្វីខ្វាសអៀនអ្វីទាំងអស់, បានចង្កៀងទិព្វដល់ដៃក៏ឈប់ពាយនាយទៀត ហើយរកផ្លូវដកថយដើម្បីអនុវត្តកម្មវិធីថ្មី ។

ក្រោយពីដោះខ្លួនបានឆ្ងាយពីវិមានអាឡាដាំង គ្រូធ្មប់អាហ្វ្រិកចាប់ផ្តើមជ្រើសផ្លូវស្ងាត់សម្រាប់ដើរ ។ គាត់ងាកឆ្វេងងាកស្តាំអត់ឃើញមានអ្នកណាទៅមកក៏គ្រវាត់ចោលទាំងកញ្ជើតាំងចង្កៀង ហើយឆ្លង



ទៅផ្លូវមួយទៀតបង្វែងដាន ។ លុះទៅដល់ខ្លោងទ្វារកំពែងក្រុង គាត់ឆ្លៀតទិញចំណីសិនទើបចេញទៅក្រៅ ។ ប្រហែលមួយម៉ោងក្រោយគាត់រកកន្លែងលាក់ខ្លួនក្នុងគម្ពោតស្ងាត់ សម្ងំនៅទីនោះរហូតដល់ព្រះអាទិត្យអស្តង្គត ទើបយកចង្កៀងទិព្វចេញ លូកម្រាមដៃដុសហៅទេពចម្លែក, គ្រាន់តែម្រាមដៃដុសខ្ទាកភ្លាម ទេពចម្លែកបង្ហាញខ្លួនសួរ :

- ចៅហ្វាយម្ចាស់ត្រូវការអីដែរ? រូបខ្ញុំនិងទេពឯទៀតជាទាសកររបស់ចង្កៀងនេះ ត្រៀមខ្លួនជានិច្ចចាំទទួលបញ្ជាពីចៅហ្វាយម្ចាស់ក៏ដូចអ្នកណាក៏ដោយដែលកាន់ចង្កៀងនេះក្នុងដៃ ។

- ចាំស្តាប់យើងនិយាយ. (គ្រូធ្មប់អាហ្វ្រិកតប) អ្នកឯងត្រូវធ្វើកិច្ចការមួយជាបន្ទាន់ គឺរំកិលវិមានដែលអ្នកឯងបានសាងសង់នៅក្នុងរាជធានី យកទាំងវិមានទាំងមនុស្សក្នុងនោះនាំទៅទ្វីបអាហ្វ្រិកដាក់នៅកន្លែងមួយទៀតឱ្យយើង ។

បន្ទាន់នឹងពាក្យប៉ុន្មានម៉ាត់ខាងលើ ទេពចម្លែកលើកទាំងគ្រូធ្មប់អាហ្វ្រិក ទាំងវិមានអាឡាដាំងហោះសំដៅទ្វីបអាហ្វ្រិក ដាក់ចុះត្រង់កន្លែងដែលគ្រូធ្មប់អាហ្វ្រិកតម្រូវ ។ កិច្ចការនេះរួចរាល់ក្នុងរយៈពេលខ្លីបំផុត ។

ឥឡូវទុករឿងគ្រូធ្មប់អាហ្វ្រិកមួយឡែក, យើងបែរមើលភាពស្រឡាំងកាំងរបស់ព្រះចៅក្រុងចិនវិញ....

តាមទម្លាប់ដូចសព្វដង, ព្រឹកនោះ តើនឡើងភ្លាម ព្រះរាជាប្រញាប់ប្រញាល់យាងទៅខាងបន្ទប់ទំនេរ ទតវិមានឆើតឆាយរបស់អាឡាដាំង អច្ឆរិយវត្ថុដែលព្រះអង្គទតមិនចេះឆ្អែតព្រះនេត្រ ។ ព្រះអង្គទើបតែសម្លឹងទៅទិសទល់មុខវាំងស្រាប់តែភ្ញាក់ព្រើត, ឃើញតែវាលទទេ ។ ស្មានថាព្រិលនេត្រាស្ដេចអង្គនេះខំព្រិចៗពីរបីដងរួចសម្លឹងទៀត តែអត់ឃើញវិមាន ថ្វីបើពេលនោះ ព្រះអាទិត្យរះច្បាស់ហើយក្ដី ។ ព្រះរាជាចាប់ផ្ដើមតក់ស្លុតរកយល់មិនរួច ហេតុអីសំណង់ធំជង្គ្រឹងវិស័យវាំងស្ដេច ស្រាប់តែបាត់ឈឹងសូន្យគ្មានបន្សល់ស្លាកស្នាមបន្តិចសោះ ។ “យើងអត់ច្រឡំទេ, (ព្រះរាជានឹកក្នុងព្រះទ័យ) វិមានអាឡាដាំងពិតជានៅកន្លែងនោះ ។ បើវារលំចុះយ៉ាងហោចក៏បន្សល់ពុំនូកសម្ភារៈបាក់បែក ឬបើវាស្រុតក្នុងដីក៏ត្រង់នោះកើតជារណ្ដៅធំដែរ ហេតុអីស្អាតធេងអ៊ីចឹង?” ។

ការប្រែប្រួលដ៏ចម្លែកហួសការស្មាននេះធ្វើឱ្យព្រះរាជាច្រាស់ច្រាល់យាងចេញពីបន្ទប់ទំនេរ បញ្ជាគេទៅហៅលោកឧបរាជចូលគាល់បន្ទាន់ ។

លោកឧបរាជពុំដឹងរឿងអី ឮថាព្រះករុណាមានការប្រញាប់ក៏រត់ត្របាញ់ជើងចូលវាំង, មកដល់លុតជង្គង់ប្រណម្យសួរ :

- ក្រាបទូលព្រះករុណាជាអម្ចាស់, ថ្ងៃនេះត្រូវបើកសវនាការផង ទោះយ៉ាងណាក៏ទូលព្រះបង្គំមកក្នុងពេលបន្តិចទៀតដូចសព្វដង ។



ប៉ុន្តែព្រះអង្គមានបំណងចង់ជួបមុនដូច្នេះ ប្រហែលមានការអីសំខាន់ឬក្រាបទូល?

- ហេតុការណ៍មួយចម្លែកពេក, (ព្រះរាជាតប) អ្វីៗហាក់ដូចសមស្របតាមការយល់ឃើញរបស់លោក ជុំវិញរឿងវិមានអាឡាដាំង ។ លោកប្រាប់យើងមើល៍, វិមានអាឡាដាំងទៅណាហើយ?

- វិមានបុត្រប្រសាព្រះអង្គឬ (លោកឧបរាជបើកភ្នែកធំៗ) អម្បាញ់មិញប្រញាប់ពេកទូលព្រះបង្គំភ្លេចងាកមើល, តែវាហាក់ដូចជានៅដដែលតើ ។ វិមានធំយ៉ាងហ្នឹងងាយអីផ្លាស់ប្ដូរទីកន្លែង ?

ព្រះរាជាចង្អុលបន្ទប់ទំនេរ....

- លោកទៅខាងណោះមើលឱ្យច្បាស់សិនទៅ រួចហើយមកវិញប្រាប់យើង តើឃើញឬមិនឃើញ ?

លោកឧបរាជរត់ទៅខាងបន្ទប់ទំនេរ ឈរសម្លឹងរកវិមានអាឡាដាំង, គាត់ច្រហមាត់ធ្លុងកាលបើឃើញទីធ្លាទល់មុខវាំងអត់មានអ្វីសោះ សូម្បីស្លាកស្នាមបន្តិចបន្តួចក៏គ្មានផង ។ គាត់ត្រឡប់មកវិញទាំងមុខស្លេកស្លាំង ពុំដឹងត្រូវនិយាយថាម៉េច ។ ព្រះរាជាសួរ :

- ម៉េច, មានឃើញអីទេ?

- ក្រាបទូល, វិមានបុត្រប្រសាព្រះអង្គទៅណាបាត់ហើយ ។ ទូលព្រះបង្គំសូមទូលថ្វាយរំលឹកថាតាំងពីដំបូងម្ល៉េះ ទូលព្រះបង្គំសង្ស័យស្នាដៃអាឡាដាំង គឺជាសមិទ្ធិផលបោកប្រាស់របស់វេទមន្តធ្មប់អាប

ពុំមែនជាការពិត, ប៉ុន្តែកាលណោះព្រះអង្គហាក់ដូចពុំសូវចាប់អារម្មណ៍ឥឡូវអ្វីៗ...

ពុំមានវិធីណាបដិសេធសំដីលោកឧបរាជបាន ព្រះរាជាកាន់តែពិរោធ កាលបើឃើញថាត្រូវទទួលស្គាល់ការពិតមួយ ដែលមុននេះព្រះអង្គបដិសេធ, ពិរោធពេក ព្រះអង្គបន្លឺព្រះសូរសៀងខ្លាំងៗ :

អាបោកប្រាស់នោះទៅណាហើយ, យើងត្រូវតែកាត់ក្បាលវាចោល !

លោកឧបរាជភ័យញ័រមាត់ប៉ប៉ុក :

- ក្រាបទូលព្រះករុណាជាអម្ចាស់ដ៏មានឫទ្ធិ, ប៉ុន្មានថ្ងៃនេះអាឡាដាំងបានមកសុំព្រះអង្គទៅបរបាញ់ ។ តាំងពីពេលនោះ អត់ទាន់ឃើញត្រឡប់មកវិញទេ, ក្រាបទូល ។ ទូលបង្គំយល់ថា យើងគួរចាត់មនុស្សតាមទៅសួរគាត់ឱ្យច្បាស់លាស់សិន, គាត់ពិតជាដឹងរឿងវិមានរបស់គាត់ ។

ធ្វើរបៀបហ្នឹងដូចជាអនុគ្រោះឱ្យវាពេក, (ព្រះរាជាតប) លោកត្រូវចាត់ចែងទ័ពសេះរបស់យើងសាមសិបនាក់ឱ្យតាមចាប់វាទាំងរស់, ដាក់ច្រវាក់បញ្ជូនមកឱ្យយើងកាត់ទោស !

លោកឧបរាជអត់ហ៊ានមានយោបល់អ្វីទៀត ប្រញាប់ប្រញាល់ទៅរៀបចំកងសេះតាមបញ្ជា, ហើយផ្តែផ្តាំលោកមេទ័ពពីរបៀបអនុវត្ត ដើម្បីកុំឱ្យអាឡាដាំងគេចខ្លួនបាន ។ គាត់ខ្លាចក្រែងមេទ័ពនេះធ្វើ



ការថ្ធោះធ្លោយ មុខតែមានទោសដល់រូបគាត់ដែលជាអ្នកទទួលបញ្ជាផ្ទាល់ ។

កងសេះចេញដំណើរតែប៉ុន្មានម៉ោងក៏ជួបអាឡាដាំងកណ្តាលផ្លូវ កំពុងត្រឡប់មកពីបរបាញ់ ។ ដើម្បីកុំឱ្យអាឡាដាំងដោះខ្លួនបាន, ជួបភ្លាមពួកគេនិយាយតាមសម្រួលថា ព្រះរាជាមានការបន្ទាន់, បញ្ជាឱ្យពួកគេតាមមកអញ្ជើញនាយត្រឡប់ទៅវិញ ។

អាឡាដាំងអត់មានចាប់ភ្លឹកអ្វីសោះ ឮថាបិតាក្មេកមានការប្រញាប់ចង់ជួបក៏បំបោលសេះមកជាមួយគេ ដឹងអីមកដល់ខ្លោងទ្វារកំពែងក្រុង ស្រាប់តែត្រូវកងសេះព័ទ្ធជាប់ បន្ទាប់នោះឮលោកមេទ័ពនិយាយ :

- ជម្រាបលោកម្ចាស់, យើងត្រូវមានសេចក្តីសោកស្តាយ ដែលត្រូវជម្រាបត្រង់ថា យើងខ្ញុំទទួលព្រះរាជបញ្ជាតាមចាប់ខ្លួនលោកម្ចាស់យកទៅថ្វាយព្រះអង្គ តាមរបៀបដូចដែលគេបានអនុវត្តចំពោះពួកពានរាំង ។ សូមលោកម្ចាស់កុំប្រកែកប្រណាំងអ្វី សូមអធ្យាស្រ័យចំពោះយើងខ្ញុំ ដោយត្រូវអនុវត្តភារកិច្ចនេះទាំងបង្ខំចិត្ត ។

អាឡាដាំងមិនដែលនឹកនាខ្លួនមានកំហុសសូម្បីប៉ុនសរសៃសក់ស្រឡាំងកាំងហួសប្រមាណ សួរគេតើត្រូវកាត់ទោសរឿងអី តែមេទ័ពប្រាប់ថាទាំងរូបគាត់ ទាំងទាហានក្រោមបញ្ជាគាត់អត់ដឹងអ្វីសោះ ។ នាយសញ្ជឹងគិតបន្តិច ក៏លោតចុះពីខ្នងសេះ ប្រាប់លោកមេទ័ពនោះវិញ :